**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការបែងចែកទ្រព្យសម្បត្តិ និងការទទួលខុសត្រូវ ចំពោះបំណុលរួមក្នុងសំណុំរឿងលែងលះ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ ៖

និស្សិតឈ្មោះ កញ្ញា **ឃុន ពេជ្ររតនា**

កញ្ញា **ជសុវណ្ណ ព្រីយ៉ានុត**

សាស្ត្រាចារ្យណែនាំ ៖

លោក **គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **យុន ពេជ្ររតនា** និង នាងខ្ញុំឈ្មោះ **ជសុវណ្ណ ព្រីយ៉ានុត** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២១ បានសសេរនូវកម្រងសារណាមួយនេះឡើង៖

សូមគោរពលំអោនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖

| | | | |
|---|---|---|---|
| លោកឪពុក | **យុន ស៊ីម៉ន** | អ្នកម្តាយ | **អ៊ន ចិន្តា** |
| លោកឪពុក | **ប្រាក់ ម៉ុណ្ណា** | អ្នកម្តាយ | **សរ ស៊ីនួន** |

ដែលបានផ្តល់កំណើត ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ ណែនាំ ផ្តល់ដំបូន្មាន ផ្គត់ផ្គង់គ្រប់សព្វបែបយ៉ាង ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ទាំងផ្នែកស្មារតី ក៏ដូចជាផ្នែកសម្ភារៈ តាំងពីតូចរហូតដល់ធំដឹងក្តី ដោយមិនខ្លាចហត់នឿយ ព្រមទាំងបានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនៗតាំងពីតូចរហូតមកដល់បច្ចុប្បន្ន។ គុណូបការៈ ព្រហ្មវិហារធម៌របស់លោកអ្នកមានគុណចំពោះយើងគឺពិតជាធំធេង និងរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ ទន្ទឹមនឹងការលះបង់ លោកអ្នកមានគុណទាំងពីរក៏ដើរតួយ៉ាងសំខាន់ ក្នុងការជម្រុញទឹកចិត្ត និងបណ្តុះបណ្តាលកូនៗ ដើម្បីឲ្យក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ នៅក្នុងសង្គម។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាធិការរង ព្រមទាំងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ជាមួយនឹងលោក លោកស្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសាកលវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ ក្នុងការចូលរួមបង្ហាត់បង្រៀន និងចែករំលែកបទពិសោធន៍ល្អៗ ប្រកបដោយសីលធម៌ និងមានវិជ្ជាជីវៈពិតប្រាកដ និងជួយតម្រង់ទិសដល់រូបខ្ញុំទាំងពីរនាក់ក្លាយទៅជាសិស្សល្អ និងពលរដ្ឋល្អក្នុងរយៈពេលបួន (០៤) ឆ្នាំកន្លងមកនេះ។

លោក **គង់ សុភ័ក្រ្ត** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាសាស្ត្រាចារ្យដែលបានដឹកនាំស្រាវជ្រាវចំពោះប្រធានបទសារណាបញ្ចប់ការសិក្សាមួយនេះដែលបាព្យាយាមយកពេលវេលាផ្ទាល់ខ្លួនណែនាំតាំងពីដើមរហូតបានដល់ពួកខ្ញុំទាំងពីរបញ្ចប់សារណាមួយនេះចប់សព្វគ្រប់ផងដែរ។

លោកមេធាវី **ជា វណ្ណថា** និងលោកស្រីមេធាវី **សៃ សុក្រពិសី** ដែលបានលះបង់ពេលវេលាដ៏មានតម្លៃផ្ទាល់ខ្លួនដើម្បីមកបង្ហាត់បង្រៀន ក៏ដូចជាការផ្តល់ជាមតិយោបល់និងដំបូន្មានល្អៗ ឲ្យមកយើងខ្ញុំទាំងពីរនាក់ចងក្រងជាសារណាមួយនេះបានយ៉ាងរលូនតាំងពីថ្ងៃចាប់ផ្តើមរហូតមកដល់ថ្ងៃបញ្ចប់។

ម៉្យាងវិញទៀតសូមអរគុណ **រៀមច្បង និងមិត្តនិស្សិតរួមជំនាន់ទាំងអស់** ដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានផ្តល់ដំបូន្មានល្អៗ ជួយជ្រោមជ្រែង ក៏ដូចជាលើកទឹកចិត្ត ផ្តល់មតិយោបល់ល្អៗដល់ពួកយើងផងដែរ។

ជាចុងបញ្ចប់នេះ យើងខ្ញុំទាំងពីរនាក់ សូមគោរពលំឱនកាយ និងដឹងគុណម្តងទៀតជូនចំពោះអ្នកមានគុណទាំង២ សូមឲ្យវត្ថុស័ក្តសិទ្ធិទាំងអស់តាមជួយថែរក្សាការពារ ប្រសិទ្ធពរជ័យ ជួបតែសុខចម្រើន សុខភាពល្អ អាយុយឺនយូរ និង សូមប្រកបតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានទទួលការសិក្សាថ្នាក់បរិញ្ញាបត្រអស់រយៈពេលជាង៤ឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងពីរនាក់បានទទួលចំណេះដឹងទូលំទូលាយលើមុខវិជ្ជាទាំងអស់ ក្រោមការគ្រប់គ្រង និងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់មកដល់យើងខ្ញុំទាំងពីរ។ ដោយសារការជ្រោមជ្រែង និងការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្តនេះហើយ ទើបពួកខ្ញុំទាំងពីរអាចឈានមកដល់ការចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះបាន។ការរៀបចំសរសេរសារណានេះឡើងគឺក្នុងគោលដៅដើម្បីបញ្ចប់ការសិក្សាជំនាន់ទី២១ និងដើម្បីជាផលប្រយោជន៍ក្នុងការរួមចំណែកមួយនៅក្នុងសង្គមផងដែរ។ ការតាក់តែងសារណាមួយគឺទាមទារតម្រូវឲ្យយើងខ្ញុំទាំងពីររូបមានសមត្ថភាពខ្ពស់ និងចំណេះដឹងជាអតិបរមាក្នុងការចងក្រងឡើងមក ព្រោះថាការចងក្រងសារណាមួយនេះយើងខ្ញុំ ត្រូវបានជួបប្រទះនិងការលំបាកជាច្រើន ទើបអាចទទួលបាននូវលទ្ធផលជាទីគាប់ប្រសើរបាន។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ យើងខ្ញុំទាំងពីរបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយក្រោមចំណងជើងថា “ **ការបែងចែកទ្រព្យសម្បត្តិ និងការទទួលខុសត្រូវចំពោះបំណុលរួមក្នុងសំណុំរឿងលែងលះ**” នេះឡើង។ ម្យ៉ាងវិញទៀតការស្រាវជ្រាវមួយនេះ អាចសម្រេចជាផ្លែផ្កាបាន

បណ្តាលមកពីការដឹកនាំដ៏ត្រឹមត្រូវ និងច្បាស់លាស់ពីសំណាក់សាស្ត្រាចារ្យរបស់យើងខ្ញុំគឺលោកគ្រូ **គង់ សុភ័ក្រ** ដែលលោក គឺជាសាស្ត្រាចារ្យមួយរូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំទាំងពីរក៏សង្ឃឹមថាការស្រាវជ្រាវមួយនេះ នឹងអាចចូលរួមចំណែកជាចំណេះដឹង ព្រមទាំងជាជំនួយស្មារតីសម្រាប់សិស្ស និស្សិតដែលមានបំណងចង់ស្វែងយល់ពីប្រធានបទមួយនេះ។ បន្ថែមពីលើនេះទៅទៀត យើងខ្ញុំបានខិតខំស្រាវជ្រាវទៅលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន និងសៀវភៅចងក្រងរបស់សាស្ត្រាចារ្យ និងការបោះពុម្ពផ្សាយរបស់បណ្តាក្រសួង រួមទាំងអត្ថបទជាច្រើនផ្សេងទៀត ដើម្បីតាក់តែង និងរៀបចំឲ្យបានជាអត្ថបទសារណាមួយនេះឡើង។

ហេតុនេះ យើងខ្ញុំសូមទទួលយកនូវរាល់ការរិះគន់ទាំងឡាយ ក្នុងន័យជួយស្ថាបនាដល់ស្នាដៃមួយនេះឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងថែមមួយកម្រិតទៀត។ ដោយឡែក យើងខ្ញុំ ក៏សូមធ្វើការអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនាទៅលើផ្នែកបច្ចេកទេស អក្ខរាវិរុទ្ធ និងខ្លឹមសារមួយចំនួនដែលមានភាពខ្វះចន្លោះណាមួយនៃការស្រាវជ្រាវនេះផងដែរ។

ជាទីបញ្ចប់ យើងខ្ញុំសូមឲ្យបងប្អូនមិត្តនិស្សិតទាំងអស់ក៏ដូចជាមិត្តអ្នកអាន និងសាស្ត្រាចារ្យ មេត្តាជួយកែតម្រូវ បំពេញចំណុចខ្វះខាត និងណែនាំចំពោះកំហុសឆ្គងដែលកើតមានឡើងដោយអចេតនារបស់យើងខ្ញុំដោយក្តីអនុគ្រោះ ដោយយើងខ្ញុំនឹងរង់ចាំទទួលយកដោយក្តីរីករាយជាអនេកប្បការ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ**

**ផ្នែកទី១ ៖ ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែករបស់សហព័ន្ធ** ........ ៤

កថាខណ្ឌទី១៖ ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ ........ ៤

កថាខណ្ឌទី២៖ ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្នាក់ៗ ........ ៤

**ផ្នែកទី២ ៖ គោលគំនិតនៃវិធីបែងចែកទ្រព្យសម្បត្តិ** ........ ៥

កថាខណ្ឌទី១៖ អានុភាពនៃការបែងចែកទ្រព្យករណីលែងលះ ........ ៥

១.១. អានុភាពនៃការលែងលះទៅលើឋានៈបុគ្គល ........ ៥

១.២. អានុភាពនៃការលែងលះទៅលើទ្រព្យសម្បត្តិ ........ ៦

១.៣. អានុភាពទៅលើកូន ........ ៧

កថាខណ្ឌទី២៖ ការធ្វើប្រទានកម្មទ្រព្យសម្បត្តិរួមទៅឲ្យកូន ........ ៨

**ផ្នែកទី៣៖ មធ្យោបាយក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ** ........ ៩

កថាខណ្ឌទី១៖ ការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀងពិភាក្សាគ្នា ........ ១០

កថាខណ្ឌទី២៖ ការបែងចែកទ្រព្យសម្បត្តិតាមការសម្រេចរបស់តុលាការ ........ ១១

**ជំពូកទី២**

**ការបែងចែកបំណុលនៅក្នុងសំណុំរឿងលែងលះ**

**ផ្នែកទី១៖ សញ្ញាណគតិយុត្តនៃបំណុលក្នុងស្ថានភាពលែងលះ** ........ ១៧

កថាខណ្ឌទី១៖ បំណុលដោយឡែក ........ ១៧

កថាខណ្ឌទី២៖ បំណុលរួម ........ ១៩

**ផ្នែកទី២៖ ការទទួលខុសត្រូវចំពោះបំណុលរួមក្នុងស្ថានភាពនៃការលែងលះ** ........ ១៩

កថាខណ្ឌទី១៖ ការទទួលខុសត្រូវដោយសាមគ្គី ........ ១៩

កថាខណ្ឌទី២៖ ការទាមទារអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល ........ ២១

**សេចក្តីសន្និដ្ឋាន**........................................................................................................ ២៣
**អនុសាសន៍**.............................................................................................................២៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាឱឡារិកមួយដែលធ្វើឡើងដោយបុគ្គលពីរនាក់ដើម្បីបង្កើតនូវចំណងគតិយុត្តដ៏ពិសិដ្ឋមួយជាមួយគ្នា។ ដើម្បីបង្កើតនូវចំណងអាពាហ៍ពិពាហ៍មួយដែលមានលក្ខណៈត្រឹមត្រូវ និងមានសុពលភាពតាមផ្លូវច្បាប់ គូភាគី (សំដៅទៅលើប្តី ប្រពន្ធ) ត្រូវតែគោរពនូវលក្ខខណ្ឌដែលមាននីត្យានុកូលភាព និងច្បាស់លាស់បំផុត ពីព្រោះទម្រង់នៃកិច្ចសន្យានៃរឿងអាពាហ៍ពិពាហ៍ ពុំមានភាពសាមញ្ញដូចកិច្ចសន្យាទូទៅមួយចំនួនឡើយ។ យ៉ាងណាមិញ ចំណងអាពាហ៍ពិពាហ៍ ដ៏រឹងមាំនេះអាចនឹងត្រូវបានរំលាយទៅវិញ ដោយមូលហេតុមួយចំនួនដែលមានចែងយ៉ាងប្រត្យក្សនៅក្នុងក្រមរដ្ឋប្បវេណី "តាមវិធីនៃការលែងលះ" ដែលសំដៅដល់ការរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍។ ការរស់នៅក្នុងមួយជីវិតរបស់មនុស្សម្នាក់ៗ តែងតែប្រាថ្នាចង់រៀបអាពាហ៍ពិពាហ៍មួយសមប្រកបដោយសុភមង្គលនៅក្នុងគ្រួសារ ប៉ុន្តែក្តីប្រាថ្នានោះមិនមែនសុទ្ធតែបានសម្រេចតាមការប៉ងប្រាថ្នាទាំងអស់នោះទេ អ្នកខ្លះមានសុភមង្គលរហូតដល់ចាស់ទុំរហូតដល់អវសាននៃជីវិត ប៉ុន្តែអ្នកខ្លះទៀតក៏មានការខ្វែងគំនិតទាស់ទែងគ្នារហូតឈានទៅដល់ការលែងលះក៏មាន។ ទន្ទឹមនឹងនេះ ការលែងលះក៏អាចបណ្តាលមកពីកត្តាជាច្រើនទៀត ដែលបណ្តាលឲ្យភាគីទាំងសងខាង មិនអាចរស់នៅចុះសម្រុងនឹងគ្នាពោលគឺ ភាគីនីមួយៗយល់ឃើញថា ទំនាក់ទំនងរវាងប្តីប្រពន្ធរបស់ពួកគេគឺត្រូវតែបែកផ្លូវគ្នា។ ការលែងលះមិនត្រឹមតែបានកាត់ផ្តាច់នូវចំណងនៃអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ តែក៏ជះឥទ្ធិពលទៅលើការបែងចែកទ្រព្យសម្បត្តិ សិទ្ធអំណាចក្នុងការគ្រប់គ្រងថែរក្សាកូន សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនីមួយៗក្រោយការលែងលះ ឋានៈរបស់បុគ្គល និងបញ្ហាផ្សេងដទៃទៀតជាច្រើន។ នៅក្នុងការអនុវត្តជាក់ស្តែង ប្តីប្រពន្ធ ដែលលែងលះគ្នា ខណៈពេលដែលពួកគេត្រូវទទួលខុសត្រូវចំពោះបំណុលរួម ហើយមានករណីដែលប្តីប្រពន្ធធ្វើកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួម ដោយក្នុងនោះពួកគេព្រមព្រៀងគ្នាបែងចែកបន្ទុកទទួលខុសត្រូវចំពោះបំណុលរួមផងដែរ ដូចជាកំណត់ឲ្យប្តីប្រពន្ធទទួលបន្ទុកម្នាក់ ១ភាគ២ ជាអាទិ៍។ ភាគី បានស្នើសុំអោយតុលាការធ្វើការបែងចែកបន្ទុកក្នុងការទទួលខុសត្រូវចំពោះបំណុលរួម(បែងចែកបំណុល) តាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងបែងចែកបំណុលនៅក្នុងសេចក្តីសម្រេចលែងលះ។ ដោយហេតុថាការលែងលះ នឹងនាំអោយកើតមាននូវការផ្លាស់ប្តូរយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃឋានៈបុគ្គល និងការបែងចែកទ្រព្យសម្បត្តិ ដូច្នេះបណ្តឹងលែងលះដោយការព្រមព្រៀងត្រូវតែបញ្ជាក់ អំពីមូលហេតុនៃការស្នើសុំលែងលះ ក៏ដូចជាការស្នើសុំបែងចែកទ្រព្យផងដែរ ពីព្រោះប្រសិនបើគ្មានការ បង្ហាញឆន្ទៈបុគ្គលក្នុងការបែងចែកទ្រព្យទេ នោះតុលាការក៏មិនអាចនឹងសម្រេចអំពីបញ្ហាទ្រព្យបានដែរ។

ហេតុនេះបានជា ក្រសួងយុត្តិធម៌ សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (J I C A) បានបង្កើតឡើងនូវក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើនៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៦។ ម្យ៉ាងវិញទៀតនៅក្នុងក្រមនេះ ក៏បានបញ្ជាក់អំពីការលែងលះរវាងប្តីប្រពន្ធផងដែរ។

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើនេះ យើងខ្ញុំបានធ្វើការស្រាវជ្រាវ និងជ្រើសរើសឯកសារជាមូលដ្ឋានមួយចំនួនដើម្បីសរសេរជាសារណាមួយនេះឡើង ដែលឯកសារទាំងនោះរួមមាន ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (២១ ធ្នូ ២០០៧) សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ភាគទី៥ ។

ជាបន្តទៅនេះ នៅក្នុងសារណាមួយនេះ នឹងបានបង្ហាញអំពីសញ្ញាណរបស់ខ្លឹមសារនៃប្រធានបទដូចតទៅ៖

ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ (ជំពូកទី១) ព្រមទាំង ទ្រព្យសម្បត្តិរួមនិងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ (ផ្នែកទី១) គោលគំនិតនៃការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ (ផ្នែកទី២) ហើយនៅក្នុងនោះផងដែរក៏មានពាក់ព័ន្ធជាមួយនឹង អានុភាពដែលមានពាក់ព័ន្ធជាមួយនិងបុគ្គល និងអំពីមធ្យោបាយក្នុងការបែងចែកទ្រព្យសម្បត្តិក្នុងនោះផងដែរ។ ចំណែកឯជំពូកទី២ដែលជាចំណុចចុងក្រោយគេបង្អស់ យើងខ្ញុំបានបន្ថែមនូវចំណុចដែលទាក់ទិនទៅនឹងបំណុល ដោយនៅក្នុងនោះរួមមាន ការធ្វើការបកស្រាយយ៉ាងលំអិតដែលលើកឡើងអំពី សញ្ញាណគតិយុត្តនៃបំណុលក្នុងស្ថានភាពលែងលះ (ផ្នែកទី១) និងចំណុចចុងក្រោយគឺ ការទទួលខុសត្រូវបំណុលរួមក្នុងស្ថានភាពនៃការលែងលះ (ផ្នែកទី២)។

# ជំពូកទី១
# ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

# ជំពូកទី១
# ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

ការលែងលះគ្នា គឺជាការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបការពេញច្បាប់ក្នុងពេលរស់នៅទាំងពីរនាក់។ [1] នៅក្នុងករណីដែលប្តីប្រពន្ធធ្វើការលែងលះគ្នា គឺត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ និងផ្អែកតាមការពិភាក្សាទាំងសងខាង។ នៅពេលដែលមិនអាចធ្វើការពិភាក្សាគ្នាបានរវាងប្តីប្រពន្ធទេ នោះសហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែក។ សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង ការបែងចែកទ្រព្យសម្បត្តិរួមអាចធ្វើឡើងដោយធ្វើការពិចារណា ទៅលើទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត ផ្លូវកាយ និងផលប្រយោជន៍កូនជាអាទិ៍។ គេហកិច្ចត្រូវទុកថាជាតម្លៃស្មើនឹងការងារក្រៅផ្ទះផងដែរ ។[2] ក្រៅពីការទាមទារឲ្យមានការលែងលះរបស់សហព័ទ្ធក្នុងនោះផងដែរ សហព័ទ្ធក៏ពិចារណាលើការទាមទារឲ្យមានការកំណត់អំណាចមេបាទៅលើកូន ព្រមទាំងការបែងចែកទ្រព្យរួមរៀងៗខ្លួនដែរ។ តាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ស្តីពីការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះគ្នា ដោយផ្អែកតាមការពិភាក្សាគ្នារបស់ភាគីទាំងសងខាងដោយយុត្តិធម៌ គឺបែងចែកទ្រព្យសម្បត្តិតាមការពិភាក្សាគ្នា និងក្នុងករណីដែលការបែងចែកមិនពុំអាចពិភាក្សាគ្នាបានទេគឺត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធដោយផ្អែកតាមចំណុចនីមួយៗដែលមានចែងនៅត្រង់មាត្រា ៩៨០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីដែលរួមមាន៖

- សហព័ទ្ធម្នាក់ៗត្រូវទទួលបាននូវទ្រព្យដោយឡែករបស់ខ្លួន។
- បន្ថែមពីលើទ្រព្យដោយឡែក សហព័ទ្ធម្នាក់ៗត្រូវទទួលបាន ១ភាគ២ នៃទ្រព្យសម្បត្តិរួម។

ក៏ប៉ុន្តែ បើសិនជាមានករណីពិសេស និងមានការទាមទាររបស់ប្តី ឬប្រពន្ធណាម្ខាង តុលាការក៏អាចធ្វើការបែងចែកទ្រព្យសម្បត្តិរួម ដោយធ្វើការពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា៖ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។

[1] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ លេខ ០៤ក្រ, ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២, មាត្រា៣៨។

[2] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី៣។

## ផ្នែកទី១៖ ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ

នៅក្នុងទំនាក់ទំនងរវាងប្តីប្រពន្ធ ការគ្រប់គ្រង ការចាត់ចែង និងការបែងចែកទ្រព្យសម្បត្តិអាចនាំទៅរកវិវាទទាំងនៅក្នុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ ក៏ដូចជានៅពេលលែងលះ។ ជាទូទៅ នៅពេលណាដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានកាត់ផ្តាច់ ជម្លោះនៃការបែងចែកទ្រព្យសម្បត្តិរវាងសហព័ទ្ធទាំងពីរ ក៏ប្រឈមនឹងការកើតមានឡើងផងដែរ។ ដូច្នេះ ច្បាប់ត្រូវតែកំណត់ថា អ្វីទៅជាទ្រព្យសម្បត្តិរួម និងអ្វីទៅជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធជាមុនសិន។

### កថាខណ្ឌទី១៖ ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណាដែលសហព័ទ្ធទាំងសងខាង ឬមានតែម្ខាងទទួលបាននៅក្នុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន ដែលនៅក្នុងចំណងអាពាហ៍ពិពាហ៍មិនកាត់ផ្តាច់។ [34] និយាយជារួមឲ្យតែទ្រព្យសម្បត្តិដែលកើតមានឡើងនៅក្រោយពេលមានចំណងអាពាហ៍ពិពាហ៍ដូចជា៖ ប្រាក់ខែ ប្រាក់ចំណូលបានពីការប្រកបអាជីវកម្ម ផ្ទះ ដី ឡាន គឺត្រូវចាត់ទុកជាទ្រព្យរួមទាំងអស់ ទោះបីជាទ្រព្យនោះរកបានដោយសហព័ទ្ធណាមួយក៏ដោយ។

តាមបញ្ញត្តិមាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី បានកំណត់ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច ខ និងចំណុច គ នៃមាត្រា៩៧២ នៃក្រមដដែល។ ជាមួយគ្នាផងដែរ ទ្រព្យសម្បត្តិដែលជាតម្លៃតប (ដែលមិនមែនបានមកពីការចាត់ចែង) នៃទ្រព្យសម្បត្តិដោយឡែក ក៏ចាត់ចូលជាទ្រព្យសម្បត្តិរួមផងដែរ។ ពោលប្រសិនបើទ្រព្យដែលបានមកពីការជួល ឬអាចទាញប្រយោជន៍ចេញពីទ្រព្យសម្បត្តិដោយឡែក ដោយពុំបានធ្វើឲ្យបាត់បង់នូវទ្រព្យដោយឡែកនោះទេ (មិនមែនជាការចាត់ចែង) នោះទ្រព្យនោះ នឹងត្រូវចាត់ចូលជាទ្រព្យសម្បត្តិរួម។

ជាឧទាហរណ៍ នៅពេលដែលលោកភក្តី បានរៀបការជាមួយអ្នកនាងកញ្ញារួច លោកក៏បានដាក់ជួលផ្ទះរបស់លោក ដើម្បីទ្រទ្រង់ជីវភាពរស់នៅក្នុងក្រុមគ្រួសារ ក្នុងន័យនេះ លុយដែលបានមកពីការដាក់ជួលផ្ទះដែលជាទ្រព្យសម្បត្តិដោយឡែករបស់លោក ត្រូវក្លាយជាទ្រព្យសម្បត្តិរួម។ ម្តងទៀតផងដែររាល់ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួម ក្នុងនោះ ក៏រាប់បញ្ចូលទាំងប្រាក់ខែ ប្រាក់ចំណូលរបស់សហព័ទ្ធ នៅពេលដែលពួកគេបានរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ។ ប៉ុន្តែ មានមតិមួយចំនួនមានចម្ងល់ទៅលើករណី ដែលសហព័ទ្ធណាម្ខាង ជាកម្មសិទ្ធករ លើក្រុមហ៊ុន ឬភោជនីយដ្ឋានជាឧទាហរណ៍ក្នុងន័យនេះ គេគិតអំពីថ្ងៃខែឆ្នាំដែលសហព័ទ្ធបានរៀបអាពាហ៍ពិពាហ៍ ដោយចាត់

[4]ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៣។

ចូលប្រាក់ចំនេញនៃភោជនីយដ្ឋាន ឬក្រុមហ៊ុននោះទទួលបានចាប់តាំងពីថ្ងៃដែលសហព័ទ្ធរៀបការគឺជាទ្រព្យសម្បត្តិរួម ប៉ុន្តែក្រុមហ៊ុន ឬភោជនីយដ្ឋាននោះ នៅតែជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធដែលជាម្ចាស់កម្មសិទ្ធិនោះដដែល។

គោលបំណងរបស់ច្បាប់ បានកំណត់យ៉ាងច្បាស់អំពីទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ ប៉ុន្តែ ច្បាប់ក៏បានប្រកាន់នូវគោលការណ៍ សាមគ្គីភាព របស់សហព័ទ្ធនៅពេលដែលពួកខ្លួនបានរៀបអាពាហ៍ពិពាហ៍រួច ទើបទ្រព្យដែលទាញចេញពីផលប្រយោជន៍ទ្រព្យសម្បត្តិដោយឡែក និងក្លាយជាទ្រព្យសម្បត្តិរួម លើកលែងតែទ្រព្យនោះបានមកពីការចាត់ចែង (លក់) ទ្រព្យសម្បត្តិដោយឡែក ទើបវានៅតែជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្ខាងនោះដដែល។ នៅក្នុងផ្នែកទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធនេះផងដែរ យើងអ្នកសិក្សាគួរបែងចែកឲ្យដាច់នូវទ្រព្យសម្បត្តិសកម្ម និងទ្រព្យសម្បត្តិអកម្ម។ មិនខុសពីនៅក្នុងផ្នែកទ្រព្យសម្បត្តិដោយឡែកទេទ្រព្យសម្បត្តិរួម ក៏នូវមានទ្រព្យខ្លះជាទ្រព្យដែលសហព័ទ្ធមានសិទ្ធិក្នុងការចាត់ចែង ប្រើប្រាស់ និងអាស្រ័យផល (ទ្រព្យសកម្ម) ហើយទ្រព្យខ្លះ ជាទ្រព្យដែលសហព័ទ្ធទាំងសងខាងមានកាតព្វកិច្ចតបស្នងទៅកាន់ម្ចាស់បំណុលវិញផងដែរ (ទ្រព្យអកម្ម)។ បានបញ្ជាក់ពីខាងដើមរួចមកហើយ ទ្រព្យសកម្ម គឺជាទ្រព្យដែលសហព័ទ្ធទាំងសងខាង មានសិទ្ធិទាញផលប្រយោជន៍ពីវា ចំណែកឯទ្រព្យអកម្ម គឺជាកាតព្វកិច្ចដែលសហព័ទ្ធដើម្បីអនុវត្តទៅតតិយជនណាម្នាក់វិញ។ ប៉ុន្តែ ចំណុចខុសប្លែករវាងចំណុចទាំងពីរនេះគឺនៅត្រង់ ទ្រព្យសកម្មដោយឡែក គឺសហព័ទ្ធណាម្ខាងមានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ និងចាត់ចែងតាមការប៉ងរបស់ខ្លួនបានដោយសេរី ពោលគឺសម្រាប់ខ្លួនឯងឬក្រុមគ្រួសារ ក៏ដូចគ្នាទៅនឹងទ្រព្យអកម្មដោយឡែក សហព័ទ្ធម្ខាងនោះមានកាតព្វកិច្ចក្នុងការអនុវត្តទៅកាន់ម្ចាស់បំណុលរបស់ខ្លួន រីឯទ្រព្យសម្បត្តិរួមនេះ សហព័ទ្ធទាំងសងខាង មានសិទ្ធិ និងកាតព្វកិច្ចជាមួយគ្នាទៅវិញទៅមក ទាំងទ្រព្យសម្បត្តិរួមអកម្ម និងទ្រព្យសម្បត្តិរួមសកម្ម។

ជាមួយគ្នានេះដែរ មានការបកស្រាយ និងលើកអំណះអំណាងថា ទ្រព្យសម្បត្តិរួម មានចរិតលក្ខណៈស្រដៀងគ្នាទៅនឹងកម្មសិទ្ធិអវិភាគ ដែលមានចែងនៅក្នុងបញ្ញត្តិមាត្រា២០២ នៃក្រមរដ្ឋប្បវេណី ត្រង់សហកម្មសិទ្ធករ មានកម្មសិទ្ធិស្របទៅតាមសមាមាត្រ នៃចំណែករបស់ខ្លួន។ ក្នុងន័យនេះ មានន័យថាសហព័ទ្ធ ដែលជាសហម្ចាស់កម្មសិទ្ធិ មានសិទ្ធិ និងករណីយកិច្ច ក្នុងការប្រើប្រាស់ ថែទាំ គ្រប់គ្រង លើទ្រព្យសម្បត្តិរួមរបស់ពួកគេ។ ប៉ុន្តែចំណុចដែលមានលក្ខណៈពិសេសនិងខុសប្លែកពីកម្មសិទ្ធិអវិភាគគឺនៅត្រង់ថា ទ្រព្យសម្បត្តិរួម តម្រូវឲ្យមានការយល់ព្រម (ឬផ្តល់សច្ចានុមតិ) ពីសហព័ទ្ធម្ខាងទៀត មុនសហព័ទ្ធម្ខាងណានោះ អាចធ្វើការចាត់ចែងបាន ឬមានការអនុញ្ញាតពីសេចក្តីសម្រេចរបស់តុលាការផងដែរ។[5]

## កថាខណ្ឌទី២៖ ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្នាក់ៗ

ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ត្រូវបានកំណត់នៅក្នុងមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ដែលរាល់ប្រភេទទ្រព្យដែលមានចែងនៅក្នុងមាត្រានេះ នឹងចាត់ចូលជាប្រភេទទ្រព្យសម្បត្តិដោយឡែកតែម្តង។ គោលគំនិតច្បាប់ គឺតាក់តែងបញ្ញត្តិនៃមាត្រានេះ ដោយសារតែប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ជាក់ស្តែង គឺពុំមាននូវការព្រមព្រៀង ការសរសេរ និងចងក្រងនូវលក្ខខណ្ឌណាមួយពីសហព័ទ្ធ អំពីទ្រព្យសម្បត្តិពួកគេ

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៦។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៦។

ឡើយ ដូច្នេះហើយដើម្បីជៀសវាងនូវវិវាទណាមួយកើតមានឡើងនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងក្រោយពេលលែងលះនេះតែម្ដង ដែលអាចបង្កឲ្យមានភាពពិបាកបែងចែក និងស្មុគស្មាញ ទើបច្បាប់សម្រេចកំណត់នូវប្រភេទទ្រព្យទាំងនោះឲ្យពួកគេតែម្ដង។ ក្នុងនោះផងដែរទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្នាក់ៗគឺ ៖

ក. ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមានមុនពេលរៀបអាពាហ៍ពិពាហ៍។

ខ. ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ. ទ្រព្យសម្បត្តិ ដែលជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងចំណុច ក និង ខ ខាងលើ។[6] ទ្រព្យសម្បត្តិនីមួយៗ ក្នុងចំណុចនេះមានន័យថា ជាការប្ដូររូបវត្ថុនៃទ្រព្យសម្បត្តិដោយឡែកដែលមាននៅក្នុងចំណុច ក និង ខ ដោយការចាត់ចែងដូចជា៖ ការលក់ដូរជាដើម ត្រូវមានអង្គហេតុនេះច្បាស់លាស់។

នៅមុនភាគីទាំងសងខាងចុះសំបុត្រអាពាហ៍ពិពាហ៍ ប្រសិនបើភាគីទាំងពីរបានពិភាក្សា ឬធ្វើកិច្ចសន្យាជាមួយគ្នា អំពីការដាក់ទ្រព្យសម្បត្តិដោយឡែកបញ្ចូលជាទ្រព្យសម្បត្តិរួមនោះមានន័យថាពុំមានទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្នាក់ទៀតនោះឡើយ ពោលគឺវាជាទ្រព្យសម្បត្តិរួមទាំងអស់ចាប់តាំងពីពេលមានចំណងអាពាហ៍ពិពាហ៍មក។

ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ត្រូវបានកំណត់នៅក្នុងមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ដែលរាល់ប្រភេទទ្រព្យដែលមានចែងនៅក្នុងមាត្រានេះ នឹងចាត់ចូលជាប្រភេទទ្រព្យដោយឡែកទាំងអស់។ គោលគំនិតរបស់ច្បាប់ ក្នុងការតាក់តែងបញ្ញត្តិមាត្រានេះឡើងគឺដោយសារ តែប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់កំណត់ ជាក់ស្ដែងណាស់គឺពុំមាននូវការព្រមព្រៀង តាក់តែង និងចងក្រមនូវលក្ខខណ្ឌណាមួយពីសហព័ទ្ធ អំពីទ្រព្យសម្បត្តិរបស់ពួកគេឡើយដូច្នេះហើយ ដើម្បីជៀសវាងនូវវិវាទណាមួយអំឡុងពេលអាពាហ៍ពិពាហ៍ និងនៅក្រោយពេលលែងលះទើបច្បាប់សម្រេចនូវប្រភេទទ្រព្យទាំងនោះឲ្យពួកគេតែម្ដង។

តាមមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ចំណុចក ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ។ ជាការពិតណាស់ទ្រព្យសម្បត្តិដែលភាគីម្ខាងណាមាន ឬខិតខំប្រឹងប្រែងរកបានមុនពេលរៀបការ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ពួកគេ ព្រោះជាក់ស្ដែងទ្រព្យសម្បត្តិទាំងនេះ គឺពុំមានការចូលរួមពីសហព័ទ្ធម្ខាងទៀតក្នុងនាមជាប្ដី ឬប្រពន្ធរបស់គេទេ ដូច្នេះបើចាត់ចូលប្រភេទទ្រព្យសម្បត្តិនេះ ទៅក្នុងទ្រព្យសម្បត្តិរួមដែរនោះ វាហាក់បីដូចមានភាពអយុត្តិធម៌ចំពោះភាគីដែលបានរកនូវទ្រព្យសម្បត្តិទាំងនេះពេក។

ទ្រព្យសម្បត្តិទាំងនោះអាចមានដូចជា ចលនវត្ថុ (ឡាន លុយ) ឬអចលនវត្ថុ (ផ្ទះ ដី)...។ល។ ដែលសហព័ទ្ធណាម្ខាងមានមុនពេលរៀបអាពាហ៍ពិពាហ៍ជាមួយសហព័ទ្ធម្ខាងទៀត។

---

[6] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧២។

ឧទាហរណ៍៖ លោកភក្តី មានផ្ទះមួយខ្នង ឡានមួយគ្រឿង (ដែលនៅជាប់បង់រំលោះក្រុមហ៊ុន) និង លុយសុទ្ធចំនួន ១០ម៉ឺនដុល្លា ក្រោយមកលោកបានជួបនិងនារីម្នាក់ឈ្មោះកញ្ញា ពួកគេបានរៀបការជាមួយគ្នា នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។ ដូច្នេះ រាល់ទ្រព្យសម្បត្តិដែលលោកភក្តីមាន នៅមុនថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៨ ដែលជាថ្ងៃរៀបអាពាហ៍ពិពាហ៍របស់លោកជាមួយនិងលោកស្រីកញ្ញា គឺជាទ្រព្យសម្បត្តិដោយឡែក របស់លោកភក្តី។ យ៉ាងណាមិញ នៅពេលដែលគេនិយាយពីទ្រព្យសម្បត្តិ គេភាគច្រើនសម្លឹងមើលតែទ្រព្យដែល ភាគីមានសិទ្ធិចាត់ចែង ឬប្រើប្រាស់ ឬអាស្រ័យផល ប៉ុន្តែជាក់ស្តែង ពាក្យថាទ្រព្យសម្បត្តិគឺ មានអត្ថន័យក្តោប ទាំងទ្រព្យដែលជាសិទ្ធិនិងទ្រព្យដែលជាកាតព្វកិច្ចរបស់ភាគីដែលនឹងត្រូវបំពេញ។ សម្រាប់ភាសាច្បាប់ ទ្រព្យ ទាំងឡាយណាដែលជាសិទ្ធិ គេហៅថាទ្រព្យសកម្ម និងទ្រព្យទាំងឡាយណាដែលជាកាតព្វកិច្ច គេហៅថាទ្រព្យ អកម្ម។ ខាងក្រោមនេះនឹងពន្យល់បកស្រាយលំអិតអំពីប្រភេទទ្រព្យសកម្ម និងទ្រព្យអកម្ម។

**ទ្រព្យសកម្ម៖** គឺជាទ្រព្យដែលកម្មសិទ្ធករ អាចទទួលផលប្រយោជន៍បានពីវាដោយសារការយកទ្រព្យ នោះទៅប្រើប្រាស់ ចាត់ចែង ឬអាស្រ័យជាអាទិ៍។ នៅពេលគេនិយាយពីទ្រព្យសកម្ម ជាធម្មតាយើងអាចសន្មត់ ទុកជាមុនបានថាទ្រព្យទាំងនោះ ប្រាកដជាមានដូចជា ផ្ទះ ឡាន ដីធ្លី ឬអចលនវត្ថុផ្សេងៗដែលកម្មសិទ្ធករ មានសិទ្ធិពេញលេញក្នុងការចាត់ចែងទ្រព្យទាំងនោះបាន។ ឧទាហរណ៍៖ ផ្ទះដែលលោកភក្តីទិញដាច់ពីម្ចាស់ផ្ទះ ចាស់ នោះគឺជាទ្រព្យដោយឡែកសកម្មរបស់លោក ព្រមទាំងលុយសុទ្ធ១០ម៉ឺនដុល្លារបស់លោកផងដែរ។

**ទ្រព្យអកម្ម៖** គឺជាទ្រព្យដែលកម្មសិទ្ធករត្រូវបំពេញកាតព្វកិច្ចចំពោះវាវិញ ពោលគឺជាបំណុល ដែលកូន បំណុល ត្រូវបំពេញកម្មវត្ថុទៅម្ចាស់បំណុល ក្នុងន័យនេះកម្មសិទ្ធករពុំបានទទួលផលប្រយោជន៍ពីវាទេ ប៉ុន្តែត្រូវ មានកាតព្វកិច្ចចំពោះវាទៅវិញ។ ឧទាហរណ៍៖ ឡានរបស់លោកភក្តី ដែលកំពុងជាប់ការបង់រំលោះនៅក្នុងក្រុម ហ៊ុន គឺជាទ្រព្យអកម្ម ដោយសារតែលោកត្រូវសងបំណុលទាំងនោះឲ្យគ្រប់ចំនួន ដូច្នេះការបង់រំលោះឡាននោះ គឺ ជាទ្រព្យសម្បត្តិដោយឡែកអកម្មរបស់លោកភក្តី។

បញ្ញត្តិនេះ នឹងត្រូវយកមកអនុវត្តដូចគ្នាចំពោះចំណុចដទៃទៀតនៅក្នុងចំណុចទ្រព្យសម្បត្តិដោយឡែក នេះ។

តាមបញ្ញត្តិមាត្រា៩៧២ ចំណុចខ នៃក្រមដដែលនេះ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយ **ប្រទានកម្ម សន្តតិកម្ម អច្ច័យទាន** នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ត្រូវបានចាត់ចូលជាទ្រព្យសម្បត្តិដោយ ឡែករបស់សហព័ទ្ធដែរ។ នៅក្នុងក្រមរដ្ឋប្បវេណីនេះផងដែរ ត្រង់មាត្រា៥៦៨ បានឲ្យនិយមន័យពាក្យថា **ប្រទាន កម្ម** សំដៅទៅលើកិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឲ្យភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។ ដោយសារលក្ខណៈពិសេសនៃប្រទាន កម្ម គឺទាយក (ភាគីម្ខាងនៃកិច្ចសន្យាប្រទានកម្ម ដែលបង្ហាញឆន្ទៈផ្តល់ទៅឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ)[7] មានឆន្ទៈ ចង់ផ្តល់នូវកម្មវត្ថុណាមួយ មកឲបដិគ្គាហក (អ្នកដែលទទួលយកអំណោយ ឬ ភាគីម្ខាងនៃកិច្ចសន្យាប្រទានកម្ម ដែលយល់ព្រមទទួលយកនូវទ្រព្យសម្បត្តិពីទាយក ដោយមិនផ្តល់តម្លៃតប ស្នង)[8] ដោយសន្តានចិត្ត ពុំត្រូវការតបស្នងណាមួយពីភាគីម្ខាងទៀត ទើបច្បាប់យល់ឃើញថា រាល់ទ្រព្យដែល សហព័ទ្ធទទួលបានពីការធ្វើប្រទានកម្ម ពីតតិយជនណាមួយនោះ គប្បីចាត់វាចូលជាទ្រព្យសម្បត្តិដោយឡែក

[7] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ៥៣ ទំព័រ៨។

[8] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ៨២ ទំព័រ១២។

របស់សហព័ទ្ធម្ខាងនោះ ព្រោះដើម្បីគោរពដល់អ្នកបង្ហាញឆន្ទៈក្នុងការឲ្យ ឬប្រគល់វត្ថុនោះទៅឲ្យសហព័ទ្ធណាម្ខាងជាចាំបាច់។

ក្នុងនោះផងដែរ **សន្តតិកម្ម** ក៏ជាចំណែកមួយដែលសហព័ទ្ធទទួលបានជាទ្រព្យសម្បត្តិដោយឡែកផងដែរ។ តាមន័យរបស់សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី បានឲ្យនិយមន័យលើពាក្យ **សន្តតិកម្ម** គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជន ទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។ ដោយសារសន្តតិកម្ម គឺជាការកំណត់របស់ច្បាប់ ពេលបើទោះបីជាមតកជន (ជនដែលបានស្លាប់ទៅហើយ)[9] ពុំបានសសេរលិខិតបណ្តាំ អំពីអ្នកដែលទទួលទ្រព្យសម្បត្តិរបស់គាត់មុនពេលចែកឋានទៅទេ នោះច្បាប់នឹងធ្វើការបែងចែកឲ្យ ដោយផ្អែកតាមក្រមរដ្ឋប្បវេណី គន្ថីទី៨ ស្តីអំពីសន្តតិកម្មផងដែរ។ សម្រាប់សន្តតិកម្មដែលធ្វើឡើងដោយផ្អែកតាមឆន្ទៈរបស់មតកជនត្រូវបានគេហៅថាសន្តតិកម្មមានបណ្តាំ ឬមតកសាសន៍ និងសម្រាប់សន្តតិកម្មដែលមិនមានការបង្ហាញឆន្ទៈពីមតកជននោះទេ ពោលគឺតាមបញ្ញត្តិនៃច្បាប់កំណត់ ត្រូវបានគេហៅថាសន្តតិកម្មតាមច្បាប់។[10] យ៉ាងណាមិញ បើទោះបីជាការទទួលបានពីទ្រព្យសម្បត្តិណាមួយពីមតកជន តាមរយៈសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមបណ្តាំក៏ដោយ ក៏ទ្រព្យដែលសន្តតិជន (ជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម)[11] ទទួលបាននោះ ក្នុងប្រភេទជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដែរ។ នេះដោយសារតែ គោលគំនិតច្បាប់ ឲ្យតម្លៃទៅលើការបង្ហាញឆន្ទៈរបស់មតកជនជាធំ ពោលគឺដើម្បីសម្រេចបំណងប្រាថ្នារបស់ខ្លួន បន្ទាប់ពីខ្លួនបានទទួលមរណភាពទៅ ទើបច្បាប់យល់ថា ទ្រព្យដែលសហព័ទ្ធណាម្ខាងដែលទទួលបានពីសន្តតិកម្មគឺជាទ្រព្យសម្បត្តិពិសេស គប្បីចាត់ចូលជាទ្រព្យសម្បត្តិដោយឡែក។

មិនខុសពីប្រទានកម្ម និងសន្តតិកម្ម **អច្ច័យទាន** ក៏ត្រូវបានគេសន្មត់ថាជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធនៅពេលដែលពួកគេទទួលបានពីតតិយជន។ **អច្ច័យទាន** គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។[12] អនុលោមតាមមាត្រា១១៩៩ បានបែងចែក និងឲ្យនិយមន័យអច្ច័យទានជាពីរ គឺអច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ។ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់ដោយមតកសាសន៍។ ទោះជាយ៉ាងនេះក្តី ទ្រព្យសម្បត្តិដែលសហព័ទ្ធ នឹងទទួលបានតាមរយៈអច្ច័យទាន ទោះជាអច្ច័យទានសកលក្តី ឬអច្ច័យទានមានកំណត់ក្តី ក៏ច្បាប់ចាត់ទុកនូវទ្រព្យសម្បត្តិទាំងនោះ នៅក្នុងន័យជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដែរ សរុបមក បើយើងពិនិត្យមើលទៅលើលក្ខណៈសម្បត្តិរបស់ទ្រព្យសម្បត្តិដោយឡែកក្នុងចំណុចខ មាត្រា៩៧២នេះ យើងឃើញថា ទាំងប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន គឺភាគច្រើនសុទ្ធតែកើតឡើងពីការបង្ហាញឆន្ទៈ របស់បុគ្គលដែលជា ទាយក មតកជន និងម្ចាស់បណ្តាំ ក្នុងការប្រគល់នូវទ្រព្យសម្បត្តិណាមួយឲ្យទៅបុគ្គលណាម្នាក់។ ដូច្នេះហើយ តាម**គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន**[13] ក្រមរដ្ឋប្បវេណី បាន

[9] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ១១៧ ទំព័រ១៧។

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ឆ្នាំ២០០៧ មាត្រា១១៤៥។

[11] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ១៤៤ ទំព័រ២១។

[12] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ៧៧ ទំព័រ២៦។

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ឆ្នាំ២០០៧ មាត្រា៣។

ឲ្យតម្លៃ និងគោរពជាខ្លាំងទៅលើសេរីភាពឆន្ទៈរបស់បុគ្គល ក្នុងការសម្រេចចិត្ត លើប្រតិបត្តិការណាមួយ។ ជាហេតុ ធ្វើឲ្យមានតែបុគ្គលដែលជាម្ចាស់ប្រទានកម្ម ឬម្ចាស់មរត បង្ហាញឆន្ទៈប្រគល់នូវទ្រព្យសម្បត្តិណាមួយទៅឲ្យបុគ្គលនោះតែប៉ុណ្ណោះ ទើបបុគ្គលនោះមានសិទ្ធិទទួលបាននូវផលប្រយោជន៍ ឬកាតព្វកិច្ចណាមួយជាដាច់ខាត។ ដោយសារហេតុនេះហើយ ទោះបីជាទ្រព្យសម្បត្តិទាំងនោះបានកើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ក៏ចានូវតែជាប្រភេទទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធដដែល។

តាមបញ្ញត្តិមាត្រា៩៧២ ចំណុចគ នៃក្រមរដ្ឋប្បវេណី បានកំណត់ទៀតផងដែរ ថារាល់ទ្រព្យសម្បត្តិដែលជាតម្លៃតប ពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក ដែលមានចែងក្នុងចំណុច ក និង ខ នៃមាត្រាដដែលនេះ ក៏នូវតែជាទ្រព្យសម្បត្តិដោយឡែកដដែល។ ពាក្យថា ជាតម្លៃតប ពីការចាត់ចែង នៅក្នុងភាសាច្បាប់ គឺចង់សំដៅ ទៅលើការលក់ ប្រទានកម្ម ឬការដូរ ដែលជាទ្រព្យដោយឡែក (ចំណុច ក និង ខ) ដើម្បីជាប្រយោជន៍ ឬក្នុងគោលបំណងណាមួយរបស់សហព័ទ្ធ។ ក្នុងនេះផងដែរ ក៏មានមតិមួយចំនួន លើកឡើងអំពីចម្ងល់ថា ក្នុងករណីដែលសហព័ទ្ធ បានប្រើប្រាស់ទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដើម្បីយកទៅជួល តើវាជាសកម្មភាពនៃការចាត់ចែងទ្រព្យនេះដែរឬទេ? នៅក្នុងន័យច្បាប់ ប្រាក់ឈ្នួលពុំមែនជាតម្លៃតបដែលបានមកពីការចាត់ចែងនោះទេ ពោលគឺច្បាប់ពុំបានកំណត់ថា ប្រាក់ដែលបានមកពីការដាក់ជួលទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ គឺមិនមែនជាទ្រព្យសម្បត្តិដោយឡែកនោះទេ គឺវានៅតែជាទ្រព្យសម្បត្តិរួមដដែល។ ដូច្នេះ ក្នុងមាត្រានេះ តម្លៃតបដែលបានមកពីការចាត់ចែង ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធគឺមានដូចជា ការលក់ កាដូរ ឬការធ្វើប្រទានកម្មទៅឲ្យតតិយជនជាដើម។

យ៉ាងណាមិញ បើទោះបីនៅក្នុងមាត្រា៩៧២ ទ្រព្យសម្បត្តិដោយឡែក ពុំបានចែងអំពីសិទ្ធិដែលមានលក្ខណៈផ្ទាល់ខ្លួនសម្រាប់សហព័ទ្ធក៏ដោយ ក៏យើងគប្បីគួរកត់សម្គាល់ផងដែរថាទ្រព្យដែលបានមកពីសិទ្ធិផ្តាច់មុខរបស់សហព័ទ្ធ ដែលមានដូចជាសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ចជាដើម ក៏ច្បាប់បានចាត់ទុកវាជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធផងដែរ ដោយពុំអាចយកមកបែងចែកជាមួយនឹងទ្រព្យរួមបានឡើយ។ ក្នុងន័យនេះ មានន័យថាបើសិនជាសហព័ទ្ធណាម្ខាងបានទទួលអាហារកាតព្វកិច្ចនៅមុនពេលអាពាហ៍ពិពាហ៍ ឬអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ក៏ប្រាក់នោះជាទ្រព្យដោយឡែករបស់សហព័ទ្ធនោះ តែនៅក្នុងករណីកំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ក៏ប្រាក់នោះជាទ្រព្យដោយឡែករបស់សហព័ទ្ធនោះ តែនៅក្នុងករណីកំឡុងអាពាហ៍ពិពាហ៍ប្រាក់ដែលគេទទួលបាននោះ ត្រូវប្រើប្រាស់ជាទ្រព្យរួម ដោយឡែកសម្រាប់ពេលលែងលះអាហារកាតព្វកិច្ចពុំបានត្រូវបែងចែកទៅឲ្យសហព័ទ្ធម្ខាងទៀតបានឡើយ។ ឧទាហរណ៍៖ សហព័ទ្ធម្ខាងបានទទួលនូវអាហារកាតព្វកិច្ចពី ម្តាយរបស់គាត់ជារៀងរាល់ខែ ចំនួន៥០០ដុល្លាអាមេរិច ដូច្នេះទ្រព្យនេះជាទ្រព្យដោយឡែករបស់គាត់ បើទោះបីជាគាត់រៀបអាពាហ៍ពិពាហ៍ទ្រព្យនេះគាត់អាចយកមកប្រើប្រាស់ជាទ្រព្យរួមក៏ដោយ ក៏នៅពេលដែលលែងលះ សហព័ទ្ធម្ខាងទៀតពុំអាចទទួលបាននូវអាហារកាតព្វកិច្ចដោយចែកជាពីរបានទេ ពោលគឺ គេពុំអាចយកមកចែកគ្នាមួយខែម្នាក់ទទួលបាន៥០០ដុល្លាអាចមេរិចពីម្តាយរបស់សហព័ទ្ធម្ខាងណានោះបានឡើយ។[14]

[14] វុន ពណ្ណរិទ្ធ និង ចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ, (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧), ៣៥៩។

សរុបមក ទ្រព្យសម្បត្តិដោយឡែក ក៏មានការកំណត់ប្រភេទថាលក្ខណៈទ្រព្យសម្បត្តិណាជាទ្រព្យសកម្ម និងលក្ខណៈទ្រព្យសម្បត្តិណាជាទ្រព្យអកម្មផងដែរ ដោយអនុលោមទៅតាមលក្ខខណ្ឌដែលបានបកស្រាយពីនិយមន័យ ន័យទ្រព្យសកម្ម (ជាសិទ្ធិ) និងទ្រព្យអកម្មជា (កាតព្វកិច្ច ឬបំណុល) នៅខាងដើមផងដែរ។ ច្បាប់ពុំបានបកស្រាយឲ្យលំអិត ថាតើទ្រព្យអ្វីជាទ្រព្យសកម្ម ឬទ្រព្យអ្វីជាទ្រព្យអកម្មឡើយ ប៉ុន្តែច្បាប់បានកំណត់ពីវិសាលភាព ប្រយោជន៍ និងកាតព្វកិច្ចរបស់កម្មសិទ្ធករ ដោយឲ្យយើងជាអ្នកវិភាគ យកទៅអនុវត្ត ទៅតាមករណីខុសៗគ្នានីមួយៗ តែត្រូវផ្អែកទៅតាមគោលគំនិតច្បាប់ដដែល។

## ផ្នែកទី២៖ គោលគំនិតនៃវិធីបែងចែកទ្រព្យ

ដោយហេតុថាការលែងលះ នឹងនាំឲ្យកើតមាននូវការផ្លាស់ប្ដូរយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃឋានៈបុគ្គល និងការបែងចែកទ្រព្យសម្បត្តិ ដូច្នេះបណ្ដឹងលែងលះដោយការព្រមព្រៀងត្រូវតែបញ្ជាក់ អំពីមូលហេតុនៃការស្នើសុំលែងលះ ក៏ដូចជាការស្នើសុំបែងចែកទ្រព្យផងដែរ ពីព្រោះបើគ្មានការបង្ហាញឆន្ទៈបុគ្គលក្នុងការបែងចែកទ្រព្យទេ នោះតុលាការក៏មិនអាចនឹងសម្រេចអំពីបញ្ហាទ្រព្យបានដែរ។

### កថាខណ្ឌទី១៖ អានុភាពនៃការបែងចែកទ្រព្យករណីលែងលះ

#### ១.១. អានុភាពនៃការលែងលះទៅលើឋានៈបុគ្គល

ប្ដីប្រពន្ធ ដែលនៅក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក។[15] ផ្ទុយទៅវិញ កាតព្វកិច្ចខាងលើនេះនឹងត្រូវផុតរលត់ក្រោយមានការលែងលះ លើកលែងតែការផ្ដល់ អាហារកាតព្វកិច្ចដល់ប្ដី ឬប្រពន្ធ ឬកូន ដែលជាកាតព្វកិច្ចដែលចាំបាច់ នឹងមិនផុតរលត់នោះទេ។ ម៉្យាងវិញទៀត ការលែងលះតាមផ្លូវច្បាប់ ក៏បានផ្ដល់លទ្ធភាពដល់ប្ដី ឬប្រពន្ធ ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ថ្មីអាចសម្រេចទៅបានផងដែរ។ ក្នុងករណីនេះ ភាគីខាងនារីក៏ត្រូវគោរពនូវរយៈពេលមួយដែលកំណត់ដោយច្បាប់ ពោលប្រសិនបើរយៈពេល ១២០ ថ្ងៃពុំទាន់បានផុតរលត់ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោលនោះទេ អាពាហ៍ពិពាហ៍ថ្មីដែលកើតឡើងក្នុងអំឡុងពេលនោះត្រូវហាមឃាត់។[16] ដោយឡែក ចំពោះករណីអនីតិជនដែលសន្មតថាបានដល់នីតិភាពដោយសារចំណងអាពាហ៍ពិពាហ៍ ក៏នៅតែសន្មតថាជានីតិជនដដែល ទោះបីជាចំណងអាពាហ៍ពិពាហ៍ត្រូវបានកាត់ផ្ដាច់ទៅហើយក្ដី ។ លើសពីនេះទៅទៀត ប្ដី ឬប្រពន្ធ ដែលបានប្ដូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។ [17]

[15] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៦។
[16] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦២។
[17] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៥។

### ១.២. អានុភាពនៃការលែងលះទៅលើទ្រព្យសម្បត្តិ

ការបែងចែកទ្រព្យសម្បត្តិ គឺជាបញ្ហាស្មុគស្មាញមួយក្នុងចំណោមបញ្ហាដ៏ទៃទៀត ដែលកើតចេញពីការលែងលះ ។ ហេតុដូច្នេះ អានុភាពនៃការលែងលះ គឺនាំឲ្យមានការធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរវាងប្តី និងប្រពន្ធដែលមាន ។ ការជម្រះបញ្ជីទីនេះ សំដៅទៅការពិចារណាយ៉ាងល់អិតទៅលើទ្រព្យសម្បត្តិប្តី និងប្រពន្ធដែលមាន ដោយហេតុថា ទ្រព្យសម្បត្តិក្នុងអត្ថន័យនេះ អាចបែងចែកជាទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែករបស់ប្តី ឬទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ ។ ច្បាប់បានទទួលស្គាល់នូវឆន្ទៈរបស់សហព័ទ្ធក្នុងការបែងចែកទ្រព្យរួម និងទ្រព្យដោយឡែករបស់ខ្លួនតាមការព្រមព្រៀង ដោយក្នុងករណីនេះ ប្រសិនបើមានការព្រមព្រៀងណាមួយកើតឡើង ប្តីប្រពន្ធត្រូវតែធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់នូវ ទំហំ ប្រភេទ និងតម្លៃនៃទ្រព្យសម្បត្តិដែលត្រូវបែងចែក ។ ម្យ៉ាងវិញទៀត ការបែងចេញទ្រព្យសម្បត្តិត្រូវធ្វើដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។ ក្នុងករណីដែល មិនអាចមានពិភាក្សារវាងប្តី និងប្រពន្ធបាន ការបែងចែកត្រូវធ្វើឡើងដោយៈ

- សហព័ទ្ធនីមួយៗ ទទួលបានទ្រព្យសម្បត្តិដោយឡែក[18]
- បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ ត្រូវមានសិទ្ធិទទួលយក មួយភាគពីរ
- នៃទ្រព្យសម្បត្តិរួម ។[19]

ប៉ុន្តែក្នុងករណីមានការទាមទាររបស់ប្តី ឬប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែក ទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវកាយនិងផ្លូវចិត្ត វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។[20] ក្នុងការលែងលះគ្នា ភាគីដែលមានភាពខ្វះខាត ហើយគ្មានកំហុស អាចទាមទារឲ្យភាគីម្ខាងទៀតផ្តល់អាហារកាតព្វកិច្ចចំពោះខ្លួន ដែលតម្លៃនៃអាហារកាតព្វកិច្ច គឺអាស្រ័យទៅតាមស្ថានភាពធនធានរបស់ភាគីម្ខាងទៀត ។

### ១.៣. អានុភាពទៅលើកូន

នៅក្នុងគ្រួសារខ្លះ នៅពេលដែលឪពុកម្តាយបែកបាក់គ្នា ហើយឈានដល់ការលែងលះដែលជាហេតុនាំឲ្យមានការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ក៏ពួកគេមានបំណងចង់ឲ្យតុលាការធ្វើការបែងចែកទ្រព្យរួមទៅឲ្យកូនរបស់ពួកគេផងដែរ។

---

[18] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី២ ចំណុច ក។

[19] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី២ ចំណុច ខ។

[20] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី២ ចំណុច ខ ឃ្លាទី២។

ការលែងលះ មិនត្រឹមតែជះឥទ្ធិពលនៃការបែងចែកទ្រព្យសម្បត្តិជាចម្បងនោះទេ តែក៏ពាក់ព័ន្ធយ៉ាងខ្លាំងទៅដល់សិទ្ធិអំណាចរបស់គូភាគី ទៅលើការគ្រប់គ្រងថែរក្សាកូនផងដែរ ។ មានបញ្ហាប្រឈមជាច្រើនបានកើតឡើងទាក់ទិនទៅនឹងចំណុចនេះ ក្នុងករណីដែលឪពុកម្តាយឈានដល់ការព្រមព្រៀងក្នុងការប្រគល់សិទ្ធិទៅឲ្យភាគីណាមួយក្នុងការរក្សាសិទ្ធិគ្រប់គ្រងកូនបាន ។ ហេតុនេះហើយ ពេលលែងលះ គូភាគីត្រូវតែធ្វើការសម្រេចព្រមព្រៀងទៅលើការកំណត់យកឪពុក ឬម្តាយ ណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សាគ្នាជាមុន ។[21] ជាគោលការណ៍ ក្នុងករណីដែលឪពុកម្តាយបានលែងលះ គ្នានៅមុនកំណើតរបស់កូន នោះម្តាយជាអ្នកមានអំណាចមេបា ចំពោះកូនដែលបានកើតមកនោះ ។[22] តែបើក្រោយកំណើតរបស់កូន គេអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន ។ ប្រសិនបើគូភាគីមិនអាចឈានទៅដល់ការព្រមព្រៀងក្នុងការកំណត់ថាឪពុក ឬម្តាយ ជាអ្នកមានអំណាចមេបាទៅលើកូននោះទេ នោះតុលាការ ត្រូវធ្វើការសម្រេចសេចក្តីទៅតាមឥស្សរចិត្តរបស់ខ្លួនដោយពិចារណាទៅលើផលប្រយោជន៍របស់កូនជាធំ ។[23] ទោះជាយ៉ាងណាក្តី ឪពុកឬម្តាយ ដែលពុំទទួលបានអំណាចមេបាក្រោយការលែងលះគ្នា នៅតែមានសិទ្ធិចេញចូលជួបប្រាស្រ័យទាក់ទងជាមួយកូនបានជាធម្មតា ហើយក៏នៅតែភ្ជាប់ករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងកូនផងដែរ។[24]

## កថាខណ្ឌទី២៖ ការធ្វើប្រទានកម្មទ្រព្យសម្បត្តិរួមទៅឲ្យកូន

ក្នុងករណីដែលឪពុកម្តាយបានប្រគល់ទ្រព្យណាមួយរបស់ពួកគាត់ទៅឲ្យកូន ហើយកូនយល់ព្រមទទួលចំណុចនេះហៅថា ប្រទានកម្ម (អំណោយ)[25]។ ចំពោះការធ្វើអំណោយនូវទ្រព្យណាមួយទៅឲ្យកូនរបស់ខ្លួន ទោះបីជាទ្រព្យនោះជាទ្រព្យរួមរបស់ប្តីប្រពន្ធពួកគាត់ក៏ដោយ ក៏ពុំមានបញ្ហាអ្វីដែរ ប្រសិនបើប្តីប្រពន្ធឯកភាពគ្នាក្នុងការប្រគល់ទ្រព្យសម្បត្តិដែលជាទ្រព្យរួមទៅឲ្យកូន សកម្មភាពនេះតាមផ្លូវច្បាប់ហៅថា ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ[26]។[27]

---

[21] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៧ កថាខណ្ឌទី១។
[22] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៧ កថាខណ្ឌទី២។
[23] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៧ កថាខណ្ឌទី៣។
[24] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៤០ កថាខណ្ឌទី១។
[25] ប្រទានកម្ម ជាកិច្ចសន្យាដែលមានអានុភាពដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល
[26] បើគ្មានការយល់ព្រមពីប្តីប្រពន្ធសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងបានឡើយ។
[27] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៦។

ចំពោះកម្មវត្ថុនៃប្រទានកម្មគឺជាអចលនវត្ថុ ឪពុកម្ដាយ (អ្នកធ្វើអំណោយ) និងកូន (អ្នកទទួលអំណោយ) ត្រូវធ្វើតាមកិច្ចសន្យាប្រទានកម្មតាមទម្រង់នៃលិខិតយថាភូត[28] (ជាក់ស្ដែងហៅថា លិខិតអំណោយផ្ដាច់)។

បញ្ហាចោទគឺ ករណីឪពុកម្ដាយលែងលះគ្នាហើយស្នើសុំឲ្យតុលាការបែងចែកទ្រព្យសម្បត្តិរួមឲ្យទៅកូន (ប្រទានកម្ម) ជាកំហុសឆ្គងតាមផ្លូវច្បាប់។ នៅក្នុងការអនុវត្តជាក់ស្ដែងឃើញថា មានករណីខ្លះនៅពេលដែលប្ដីប្រពន្ធធ្វើការលែងលះគ្នា ទ្រព្យសម្បត្តិខ្លះ ឬទាំងស្រុងត្រូវបានស្នើសុំឲ្យតុលាការបែងចែកឲ្យទៅកូនរបស់ពួកគេ ហើយសេចក្ដីសម្រេចបញ្ចប់បានធ្វើការបែងចែកទ្រព្យសម្បត្តិរួមប្ដីប្រពន្ធទៅឲ្យកូន។

**ឧទាហរណ៍៖** ប្ដីប្រពន្ធមានផ្ទះ (លំនៅឋានគ្រួសារ) ចំនួន ០១ កន្លែង និងប្រាក់ចំនួន ២០០.០០០ ដុល្លាអាមេរិក ពួកគេបានស្នើសុំឲ្យតុលាការបែងចែកផ្ទះទៅឲ្យកូន ហើយប្រាក់ចំនួន ២០០.០០០ ដុល្លាអាមេរិក ប្ដីទទួលបាន ១០០.០០០ ដុល្លាអាមេរិក ប្រពន្ធទទួលបាន ១០០.០០០ ដុល្លាអាមេរិក។ ចំពោះករណីនេះ តុលាការមិនអាចធ្វើការបែងចែកទ្រព្យសម្បត្តិរួមតាមការស្នើសុំរបស់ភាគីប្ដីប្រពន្ធបាននោះទេ ពីព្រោះការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះគ្នា គឺជាការបែងចែកនូវទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធតែប៉ុណ្ណោះ[29] ហេតុនេះ តុលាការពុំអាចធ្វើការបែងចែកទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ទៅឲ្យតតិយជន (កូន) ក្រៅពីភាគីប្ដីប្រពន្ធបានឡើយ។ ម្យ៉ាងវិញទៀត សេចក្ដីសម្រេចអំពីការលែងលះ ជាសេចក្ដីសម្រេចដែលបានកំណត់អំពីការរំលាយចំណងអាពាហ៍ពិពាហ៍បែងចែកទ្រព្យសម្បត្តិរួម កំណត់អំពីអ្នកមានអំណាចមេបាចំពោះកូនជាអាទិ៍ ប៉ុន្តែមិនអាចកំណត់អំពីការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធនោះទេ ពីព្រោះប្រសិនបើប្ដីប្រពន្ធចាត់ចែង

ទ្រព្យសម្បត្តិរួមនោះទ្រព្យសម្បត្តិទាំងនោះ លែងក្លាយជាកម្មវត្ថុនៃការបែងចែកនៅក្នុងសេចក្ដីសម្រេចរបស់តុលាការទៀតហើយ។ ការធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធទៅឲ្យកូន ជាសកម្មភាពនៃការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ហេតុនេះ មិនមែនជាកម្មវត្ថុដែលតុលាការអាចធ្វើការកំណត់ក្នុងសេចក្ដីសម្រេចលែងលះនោះទេ។

សរុបមក ប្រសិនបើប្ដីប្រពន្ធលែងលះគ្នាហើយមានបំណងចង់ប្រគល់ទ្រព្យសម្បត្តិដែលជាទ្រព្យរួមរបស់ប្ដីប្រពន្ធទៅឲ្យកូន សូមធ្វើតាមរយៈកិច្ចសន្យាគឺគ្រប់គ្រាន់ ពុំគប្បីស្នើសុំក្នុងបណ្ដឹង ឬពាក្យសុំលែងលះនោះទេ ហើយទោះបីជាសេចក្ដីសម្រេចរបស់តុលាការបានធ្វើការបែងចែកទ្រព្យរួមប្ដីប្រពន្ធទៅឲ្យកូនក៏ដោយក៏សេចក្ដីសម្រេចនោះពុំមានអានុភាពទៅតាមផ្លូវច្បាប់ដែរ ចំពោះការបែងចែកទ្រព្យសម្បត្តិឲ្យទៅកូន។

**ផ្នែកទី៣៖ មធ្យោបាយក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ**

---

[28] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣៦ កថាខណ្ឌទី២។

[29] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០។

ការលែងលះ មិនត្រឹមតែបានកាត់ផ្តាច់នូវចំណងអាពាហ៍ពិពាហ៍មួយមុខតែប៉ុណ្ណោះទេ តែថែមទាំងបានជះឥទ្ធិពលទៅលើការបែងចែកទ្រព្យសម្បត្តិ អំណាចមេបាក្នុងការគ្រប់គ្រងថែរក្សាកូន សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនីមួយៗក្រោយធ្វើការលែងលះទៅលើឋានៈបុគ្គល និងបញ្ហាផ្សេងៗដទៃទៀតជាច្រើន។

ជាទូទៅ រាល់ពាក្យបណ្តឹងនៃការលែងលះគ្នា សហព័ទ្ធនីមួយៗតែងតែមានការទាមទារឲ្យមានការបែងចែកទ្រព្យសម្បត្តិដែលមានចាប់តាំងពីមានចំណងអាពាហ៍ពិពាហ៍។ នៅពេលដែលប្តី ឬប្រពន្ធសម្រេចចិត្តលែងលះគ្នាមានកត្តាជាច្រើនដែលពួកគេទាំងពីរនាក់ (បើលែងលះតាមការព្រមព្រៀង) ឬតុលាការ (បើជាការលែងលះមិនមែនដោយព្រមព្រៀង) ត្រូវគិតគូរនូវចំណុចផ្សេងៗដែលត្រូវបែងចែក។ យោងទៅតាមបញ្ញត្តិមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ស្តីពីការបែងចែកទ្រព្យសម្បត្តិ កថាខណ្ឌទី១ បានកំណត់អំពីការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះគ្នា ដោយផ្អែកតាមការពិភាក្សាគ្នាដោយភាគីទាំងសងខាងដោយយុត្តិធម៌ និងកថាខណ្ឌទី២ បានកំណត់អំពីករណីដែលមានការបែងចែកពុំអាចពិភាក្សាគ្នាបានទេនោះ សហព័ទ្ធអាចដាក់ពាក្យបណ្តឹងប្តឹងទៅតុលាការក្នុងការសម្រេចសេចក្តីបាន។

## កថាខណ្ឌទី១៖ ការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀងពិភាក្សាគ្នា

ដោយអនុលោមតាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី សហព័ទ្ធអាចដាក់ពាក្យសុំលែងលះទៅតុលាការបាន[30] ក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាអំពីការលែងលះគ្នាហើយតុលាការនឹងសម្រេចឲ្យលែងលះគ្នា នៅពេលដែលគាត់យល់ថាភាគីទាំងសងខាងពិតជាមានបំណង ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ពិតប្រាកដមែន។ បើមានការទាមទារទ្រព្យសម្បត្តិ ភាគីទាំងពីរអាចពិភាក្សាគ្នាអំពីការបែងចែកទ្រព្យសម្បត្តិដោយឆន្ទៈព្រមព្រៀងរបស់ភាគីទាំងពីរបាន ហើយក្នុងករណីនេះទោះបីជាទ្រព្យសម្បត្តិដោយឡែក ឬជាទ្រព្យសម្បត្តិរួមក៏ដោយ បើមានការលះបង់ ឬការផ្តល់សម្បទានរវាងគ្នា និងគ្នាក្នុងការបែងចែក តុលាការត្រូវធ្វើការបែងចែកទៅតាមការព្រមព្រៀងនោះ។ ប្រការដែលសំខាន់ គឺការព្រមព្រៀងនោះត្រូវកើតចេញដោយឆន្ទៈដោយសេរី និងពិតប្រាកដរបស់ភាគីទាំងពីរ (មាត្រា៩៨០ កថាខណ្ឌទី១) ។ នៅមុនពេលតុលាការបានធ្វើការសម្រេចលើពាក្យសុំលែងលះរបស់សហព័ទ្ធ តុលាការគប្បីត្រូវពិចារណាទៅលើឆន្ទៈរបស់គូភាគីក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍នេះដោយត្រូវប្រាកដថាពួកគេ ពិតជាមិនអាចរួមរស់នៅជាមួយគ្នាបន្តទៅទៀតបានឡើយ ដោយធ្វើការកោះហៅភាគីសម្រាប់ធ្វើការសាកសួរពីចេតនា និងបញ្ហាផ្សេងៗដែលជាដើមចមដែលពួកគេពុំអាចបន្តអាពាហ៍ពិពាហ៍នេះតទៅមុខទៀតបាន។ លើសពីនេះទៅទៀតក្នុងករណីនៃការបែងចែកទ្រព្យតាមការពិភាក្សាគ្នានេះមានពេលខ្លះវាជាការលាក់ទុកនូវទ្រព្យសម្បត្តិពិតប្រាកដដែលអាចមានជាឧទាហរណ៍៖ ដូចជាបើប្តីលែង

[30] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង , លេខ នស/រកម/០៧១០/០៣, ១០ កក្កដា ២០១០ តារាងឧបសម្ព័ន្ធផ្នែកទី៤ ចំណុច៥។

លះជាមួយប្រពន្ធហើយចែកទ្រព្យគ្នាដើម្បីមានបំណងរត់គេចពីការដេញដោលពីសំណាក់ម្ចាស់បំណុល។ ដូច្នេះ ចំនួនទឹកប្រាក់នៃចំណែកទ្រព្យសម្បត្តិមានច្រើនហួសហេតុខុសពីខ្លឹមសារដែលមានចែងក្នុងមាត្រា៩៧៥ ចំណុច ខ ហើយបើសិនជាមានព្រឹត្តិការណ៍ពិសេស ដែលនាំឲ្យមានការយល់ឃើញថា មានការចែកទ្រព្យនេះគឺជាវិធីចាត់ចែងទ្រព្យដោយបន្លំគេអាចចាត់ទុកចំនួនទាំងអស់ ឬមួយផ្នែកនៃទ្រព្យនោះថាជាកម្មវត្ថុដែលត្រូវលុបចោលដោយអនុវត្តសិទ្ធិលុបចោលជាអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍។ នៅក្នុងពាក្យសុំលែងលះនេះផងដែរ សហព័ទ្ធគប្បីកំណត់អំពីការព្រមព្រៀងលើការលែងលះគ្នា ការកំណត់អំពីអ្នកមានអំណាចមេបាលើកូន ព្រមទាំងការបែងចែកទ្រព្យសម្បត្តិរួមផងដែរ។ នៅពេលនោះ តុលាការនឹងពិនិត្យមើលទៅលើមូលហេតុ និងភាពយុត្តិធម៌នៃការបែងចែកចំណែកទ្រព្យសម្បត្តិ ដើម្បីធានាថាការបែងចែកទាំងនេះប្រព្រឹត្តទៅដោយពុំមានការបង្ខិតបង្ខំពីភាគីណាម្ខាងឡើយ។ នីតិវិធីបន្តតុលាការនឹង ចេញសេចក្តីសម្រេចលើពាក្យសុំលែងលះរបស់សហព័ទ្ធ រួចពួកគេអាចយកសេចក្តីសម្រេចនេះទៅអនុវត្តតាមផលប្រយោជន៍ដែលមានកំណត់រៀងៗខ្លួនបាន។

ដោយឡែក ប្រសិនបើការពិភាក្សាពុំអាចឈានដល់ការព្រមព្រៀងគ្នា (អាចចូលក្នុងចំណុចផ្សេងៗទៀតដែលមានចែងក្នុងមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី) ទៅលើចំណុចទាំង២ខាងលើទេ (ការកំណត់យកអ្នកមានអំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិរួម) នោះសហព័ទ្ធអាចដាក់ពាក្យបណ្តឹងលែងលះមកតុលាការដើម្បីឲ្យចេញសាលក្រមសម្រេចអំពីអ្នកមានអំណាចមេបា និងការបែងចែកទ្រព្យរួមផងដែរ។

### កថាខណ្ឌទី២៖ ការបែងចែកទ្រព្យសម្បត្តិរួមតាមការសម្រេចរបស់តុលាការ

នៅពេលដែលពាក្យបណ្តឹងលែងលះ ឬពាក្យសុំលែងលះត្រូវបានដាក់ទៅតុលាការប្តី ឬប្រពន្ធ អាចទាមទារឲ្យតុលាការបែងចែកទ្រព្យសម្បត្តិរួមបាន ប្រសិនបើប្តីប្រពន្ធពុំអាចពិភាក្សាបែងចែកទ្រព្យរួមតាមការព្រមព្រៀង។ កាលបើការពិភាក្សារបស់ភាគីទាំងពីរ មិនបានសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិទេ បើភាគីណាមានភស្តុតាងបញ្ជាក់អំពីទ្រព្យសម្បត្តិរួម (មាត្រា៩៧៣) បើទោះក្នុងចំណោមនោះមានសហព័ទ្ធណាម្ខាងបានបំពេញតែការងារគេហកិច្ចក៏ដោយ ក៏ការងារនោះមានតម្លៃស្មើនឹងការងារដែលនៅក្រៅផ្ទះដែរ (មាត្រា៩៨០ កថាខណ្ឌ៣)។ ដូច្នេះ ទ្រព្យសម្បត្តិរួម ត្រូវបែងចែកឲ្យសហព័ទ្ធម្នាក់ៗ ចំនួន ១/២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម (មាត្រា៩៨០ កថាខណ្ឌទី២ ចំណុចខ វាក្យខណ្ឌទី១)។ ដោយផ្អែកតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី២ បានចែងថា ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិតាមការកំណត់របស់ច្បាប់ ដោយដំបូងគេសិក្សាលើទ្រព្យសម្បត្តិដោយឡែកដែលសហព័ទ្ធមាន ស្របតាមបញ្ញត្តិមាត្រា៩៧២ នៃក្រមដដែលនេះ ព្រមទាំងទ្រព្យសម្បត្តិរួម តាមសមាមាត្រនៃចំណែករបស់ភាគីទាំងសងខាង។

ជាមួយគ្នានេះដែរ ការបែងចែកទ្រព្យសម្បត្តិរួម មិនតម្រូវជាដាច់ខាតនូវការបែងចែកជាពីរចំណែកស្មើគ្នានោះទេ ក្នុងនោះដែរតុលាការនឹងពិចារណាទៅលើករណីពិសេស ដែលមានការទាមទារពីសហព័ទ្ធណាម្ខាងនូវ

ចំណែកផ្សេងៗ ដោយមើលទៅលើស្ថានភាពដូចជា៖ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទៅលើលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ ព្រមទាំងកម្រិតនៃជីវភាពរស់នៅក្នុងពេលអាពាហ៍ពិពាហ៍ ដោយបូករួមទាំងអាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។ ជាក់ស្តែង នៅក្នុងបណ្តឹងលែងលះ ការទាមទារឲ្យមានការលែងលះគ្នាគឺជាលក្ខខណ្ឌចម្បងនៃនីតិវិធីលែងលះ ចំណែកឯលក្ខខណ្ឌបន្ទាប់បន្សំ គឺមានការកំណត់អំណាចមេបាដែលអាចស្នើសុំបានតាមនីតិវិធីបណ្តឹងស្តីពីឋានៈបុគ្គល និងការបែងចែកទ្រព្យ ដែលអាចស្នើសុំតាមក្រោយបាន តាមនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង។ បើយើងក្រឡេកមកសិក្សាអំពី ការបែងចែកទ្រព្យសម្បត្តិតាមតុលាការវិញ ចៅក្រមដែលជាអ្នកសម្រេចសេចក្តី ត្រូវពិចារណា ពិនិត្យឲ្យគ្រប់ជ្រុងជ្រោយថាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធមានទំហំប៉ុណ្ណា ហើយថាតើការបែងចែកនោះទៀតសោតអាចនឹងប៉ះពាល់ដល់ផលប្រយោជន៍កូនដែរឬអត់ ពីព្រោះថាច្បាប់មានគោលគំនិតការពារដល់ផលប្រយោជន៍កុមារជាធំ។ បន្ទាប់ពីមានការសិក្សាលើចំណុចទាំងអស់នេះហើយ តុលាការ នឹងអាចចេញនូវសេចក្តីសម្រេចដ៏ត្រឹមត្រូវ និងយុត្តិធម៌ប្រកបដោយភាពសមស្របមួយដែលអាចទទួលយកបាន ដើម្បីឲ្យភាគីដែលជាសហព័ទ្ធទាំងសងខាងយកទៅអនុវត្ត។

សម្មតិកម្មខាងក្រោមនឹងបង្ហាញអំពីស្ថានភាពពិសេសនេះ ៖

⇒ “ ក” ជាប្តី “ ខ” ប្រពន្ធ

⇒ “ ខ” បានដាក់ពាក្យបណ្តឹងលែងលះ “ ក” និងទាមទារឲ្យតុលាការបែងចែកទ្រព្យរួម

⇒ ទ្រព្យសម្បត្តិសរុបមាន 20,000 ( ពីរម៉ឺន ) ដុល្លាអាមេរិក ( ប្រាក់សន្សំ 5,000 ( ប្រាំពាន់ ) ដុល្លាអាមេរិក និងដី L តម្លៃបច្ចុប្បន្ន 15,000 ( មួយម៉ឺនប្រាំពាន់ ) ដុល្លាអាមេរិក )

⇒ ដី L ពេលទិញតម្លៃ 10,000 ( មួយម៉ឺន ) ដុល្លាអាមេរិក ដោយបានយកលុយដែលជាទ្រព្យដោយឡែករបស់ “ ក” ចំនួន 8,000 ( ប្រាំបីពាន់ ) ដុល្លាអាមេរិក និងលុយរួមចំនួន 2,000 ( ពីរពាន់ ) ដុល្លាអាមេរិក។ “ ក” បានស្នើសុំឲ្យតុលាការបែងចែកចំណែកដី L មកឲ្យខ្លួនក្នុងចំណែកច្រើនជាង “ ខ” ដោយសំអាងថា “ ក” បានបរិច្ចាគទ្រព្យដោយឡែកជាច្រើនក្នុងការទិញដី L ដែលជាទ្រព្យរួម។

តើតុលាការបែងចែកទ្រព្យសម្បត្តិរួមយ៉ាងដូចម្តេច ?

1. ចំពោះប្រាក់ 5,000 ( ប្រាំពាន់ ) ដុល្លាអាមេរិក តុលាការនឹងសម្រេច ផ្អែកតាមគោលការណ៍ ១ ភាគ ២ ម្នាក់នៃសិទ្ធិលើចំណែកទ្រព្យរួម ហេតុនេះប្តីទទួលបានប្រាក់ 2,500 ( ពីរពាន់ប្រាំរយ ) ដុល្លាអាមេរិក ហើយប្រពន្ធទទួលបានប្រាក់ 2,500 ( ពីរពាន់ប្រាំរយ ) ដុល្លាអាមេរិក។

2. បើតុលាការទទួលស្គាល់ការទាមទាររបស់ “ ក” ដែលបានអះអាងអំពីទំហំនៃការបរិច្ចាគនូវទ្រព្យដោយឡែក ក្នុងការទិញដី L ហេតុនេះ តុលាការនឹងការបែងចែកតាមទំហំនៃការបរិច្ចាគនោះ។

- តម្លៃដី L ពេលទិញ = 10,000 ដុល្លាអាមេរិក
- តម្លៃដី L បច្ចុប្បន្ន = 15,000 ដុល្លាអាមេរិក
- ទំហំនៃការបរិច្ចាគ = 8,000 ដុល្លាអាមេរិក
- លុយរួមដែលយកមកទិញដី L = 2,000 ដុល្លាអាមេរិក

តាមសម្មតិកម្មខាងលើនេះ តុលាការបែងចែកទ្រព្យសម្បត្តិរបស់ប្តី ប្រពន្ធខាងលើនេះដូចតទៅ៖ តុលាការទទួលស្គាល់ថាទំហំនៃការបរិច្ចាគរបស់ “ ក” ដែលមានចំពោះទ្រព្យរួមគឺមានចំនួន 8,000 ដុល្លាអាមេរិក និងធៀបជាមួយតម្លៃដីនៅពេលទិញ (10,000 ដុល្លាអាមេរិក) គឺស្មើនឹង 8/10 នៃតម្លៃដីសរុបនាពេលទិញ ចំណែកលុយចំនួន 2,000 ដុល្លាអាមេរិកដែលជាទ្រព្យរួមប្តី ប្រពន្ធ បើធៀបនឹងតម្លៃដីនៅពេលទិញ គឺស្មើនឹង 2/10។

តម្លៃដី L នៅពេលទិញ




តុលាការទទួលស្គាល់ថាតម្លៃដីនាពេលលែងលះគឺ 15,000 ដុល្លាអាមេរិក ហេតុនេះតុលាការទទួលស្គាល់ថាទំហំនៃការបរិច្ចាគរបស់ “ក” (ប្តី) ដែលមានចំពោះទ្រព្យរួមគឺមានចំនួន 12,000 ដុល្លាអាមេរិក និងទ្រព្យសម្បត្តិរួមប្តី ប្រពន្ធមានចំនួន 3,000 ដុល្លាអាមេរិក។

តម្លៃដី L នៅពេលលែងលះ




ជាធម្មតា តុលាការនឹងបែងចែកតម្លៃដី L នេះជាពីរចំណែកស្មើគ្នាទៅឲ្យប្តីប្រពន្ធ ដោយប្តីទទួលបាន 7,500 ដុល្លាអាមេរិក និងប្រពន្ធទទួលបាន 7,500 ដុល្លាអាមេរិក ប៉ុន្តែដោយសារមានការទាមទារពីប្តី និងតុលាការទទួលស្គាល់ទំហំនៃបរិច្ចាគនៃទ្រព្យដោយឡែករបស់ប្តីនៅក្នុងទ្រព្យរួមដែលជាដី L នេះតម្រូវឲ្យតុលាការមិនអាចបែងចែកដី L នេះតាមចំណែកស្មើគ្នានោះទេ ត្រូវដកចេញនូវទំហំបរិច្ចាគរបស់ប្តីដែលមានចំនួន 12,000 ដុល្លាអាមេរិក ហេតុនេះទឹកប្រាក់ដែលនៅសល់ (15,000 – 12,000 = 3,000) ទើបធ្វើការបែងចែកទៅឲ្យប្តីនិងប្រពន្ធ

ទៅតាមចំណែកស្មើៗគ្នាមានន័យថាទឹកប្រាក់ 3,000 ដុល្លាអាមេរិកនេះនឹងបែងចែកជាពីរចំណែកដោយប្តីទទួលបាន 1,500 ដុល្លាអាមេរិក ហើយប្រពន្ធទទួលបាន 1,500 ដុល្លាអាមេរិក។




ផ្អែកលើមូលដ្ឋាននេះ បច្ចុប្បន្នដី L មានតម្លៃ 15,000 ដុល្លាអាមេរិក ហេតុនេះ ចំណែកប្រាក់ដែល ក ប្តី អាចទទួលបានពីដី L នេះគឺ 12,000 + 1,500 = 13,500 ដុល្លាអាមេរិក រីឯចំណែកប្រាក់ដែល ខ ប្រពន្ធ អាចទទួលបានពីដី L នេះគឺ 1,500 ដុល្លាអាមេរិក។




ចំណែករបស់ “ ក”
$13,500

ចំណែករបស់ “ ខ”
$1,500

សរុបមកលទ្ធផលនៃការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ៖

- “ ក” (ប្ដី) នឹងទទួលបាន 2,500 (1/2 នៃប្រាក់សន្សំ) + 13,500 (9/10 នៃដីL ) = 16,000 ដុល្លាអាមេរិក។
- “ ខ” (ប្រពន្ធ) នឹងទទួលបាន 2,500 (1/2 នៃប្រាក់សន្សំ) + 1,500 (1/10 នៃដីL ) = 4,000 ដុល្លាអាមេរិក។

ម្យ៉ាងវិញទៀត យើងអាចនិយាយបានថា តុលាការកំណត់សិទ្ធិនៃចំណែករបស់ “ ក” (ប្ដី) គឺ 9/10 នៃដី L រីឯ “ ខ” (ប្រពន្ធ) គឺ1/10 នៃដី L មិនមែន ១ ភាគ ២ ម្នាក់នៅលើដី L ឡើយ។

# ជំពូកទី២
# ការបែងចែកចំពោះបំណុល
# ក្នុងសំណុំរឿងលែងលះ

# ជំពូកទី២
# ការបែងចែកបំណុលនៅក្នុងសំណុំរឿងលែងលះ

នៅក្នុងការអនុវត្តជាក់ស្តែង ប្តីប្រពន្ធដែលលែងលះគ្នា ខណៈពេលដែលដែលពួកគេត្រូវទទួលខុសត្រូវចំពោះបំណុលរួម មានករណីដែលប្តីប្រពន្ធធ្វើកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួមដោយក្នុងនោះពួកគេព្រមព្រៀងគ្នាបែងចែកបន្ទុកទទួលខុសត្រូវចំពោះបំណុលរួមផងដែរ ដូចជាកំណត់ឲ្យប្តីជាអ្នកទទួលខុសត្រូវបំណុលរួមតែម្នាក់ឯង ឬឲ្យប្រពន្ធជាអ្នកទទួលបន្ទុកតែម្នាក់ ១ភាគ២ ជាអាទិ៍។ ជាទូទៅ ភាគីបានស្នើសុំឲ្យតុលាការធ្វើការបែងចែកបន្ទុក ក្នុងការទទួលខុសត្រូវចំពោះបំណុលរួម (បែងចែកបំណុល) តាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងបែងចែកបំណុល នៅក្នុងសេចក្តីសម្រេចលែងលះផងដែរ។

ឆ្លើយតបចំពោះបញ្ហានេះ យើងខ្ញុំសូមធ្វើការបកស្រាយបញ្ជាក់អំពីការព្រមព្រៀងបែងចែកបន្ទុកក្នុងការទទួលខុសត្រូវចំពោះបំណុលរួមរបស់ប្តីប្រពន្ធ ពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ តុលាការមិនអាចសម្រេចតាមអ្វីដែលភាគីស្នើសុំបានទេ ពីព្រោះថាការទាមទាររបស់គូភាគី គឺជាការទាមទារដែលមិនស្របច្បាប់ ហើយទោះបីជាមានករណីដែលតុលាការ សម្រេចបែងចែកបន្ទុកក្នុងការទទួលខុសត្រូវចំពោះបំណុលរួមប្តីប្រពន្ធនៅក្នុងសេចក្តីសម្រេចលែងលះក៏ពិតមែនក៏ដោយ ក៏សេចក្តីសម្រេចនោះពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ។ ហេតុផលគឺ៖

- ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព (រួមគ្នា) ទោះបីជាបានធ្វើការលែងលះគ្នាក៏ដោយ ក៏នៅតែត្រូវទទួលខុសត្រូវរួមគ្នាដែរ ប្រសិនបើឲ្យប្តីប្រពន្ធ (កូនបំណុល) ធ្វើការបែងចែកបំណុលរួមដូចជា ១ ភាគ ២ ម្នាក់នឹងនាំឲ្យបំពានផលប្រយោជន៍របស់ម្ចាស់បំណុល (ផលប្រយោជន៍ដែលម្ចាស់បំណុលអាចប្តឹងទាមទារឲ្យទាំងប្តី ទាំងប្រពន្ធអនុវត្តកាតព្វកិច្ចទាំងអស់)។
- ការសម្រេចក្នុងការចាត់ចែងបំណុលនោះបែបណា (ទាមទារពីប្តី ទាមទារពីប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធ ឬលើកលែងបំណុល) គឺជាសិទ្ធិសម្រេចរបស់ម្ចាស់បំណុល មិនមែនជាសិទ្ធិសម្រេចរបស់កូនបំណុលទេ ហេតុនេះប្តីប្រពន្ធជាកូនបំណុល មានកាតព្វកិច្ចសងបំណុលដោយរួមគ្នា ពុំអាចធ្វើការចាត់ចែងបំណុលនោះដោយខ្លួនឯងដោយការព្រមព្រៀងបែងចែកបំណុលបានទេ។

## ផ្នែកទី១៖ សញ្ញាណគតិយុត្តនៃបំណុលក្នុងស្ថានភាពលែងលះ

### កថាខណ្ឌទី១៖ បំណុលដោយឡែក

បំណុលដោយឡែក សំដៅលើបំណុល ឬកាតព្វកិច្ចដែលមានអត្ថិភាពមុនពេលមានចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធ ឬប្រទានកម្មដែលមានបន្ទុក ឬតម្លៃនៃការចាត់ចែងទ្រព្យដោយឡែក(ដូចជាការលក់ទ្រព្យដោយឡែកសម្រាប់សងបំណុលដោយឡែក ប៉ុន្តែវានៅមិនគ្រប់គ្រាន់)។ ជាងនេះទៅទៀត ចំពោះ

បំណុល ឬកាតព្វកិច្ចដែលប្តី ឬប្រពន្ធតែម្ខាងជាអ្នកបង្កើតដែលមិនពាក់ព័ន្ធនឹងសោហ៊ុយដើម្បីរក្សាជីវភាពរួម ឬផលប្រយោជន៍គ្រួសារ ឬការគ្រប់គ្រងថែរក្សាទ្រព្យរួម មិនមែនជាបំណុលរួមទេ ពោលគឺជាបំណុលដោយឡែកដូចគ្នា។ បំណុលដោយឡែក អាចចាត់ទុកថាជាទ្រព្យអកម្មដោយឡែករបស់សហព័ទ្ធណាម្ខាង ដែលសហព័ទ្ធនោះត្រូវតែទទួលបន្ទុកអនុវត្ត។

ជាគោលការណ៍ ក្នុងចំណងអាពាហ៍ពិពាហ៍ បានបង្កើតនូវអានុភាពគតិយុត្តទៅលើគូភាគី ចំពោះកូន និងទៅលើទ្រព្យសម្បត្តិ។ យ៉ាងណាមិញ ករណីមានការលែងលះ ក៏ត្រូវយកមកអនុវត្តដូចគ្នា ពោលគឺការបង្កើតនូវអានុភាពទៅលើភាគីដែលជាសហព័ទ្ធ និងទ្រព្យសម្បត្តិ។ ដោយហេតុថា ក្រមរដ្ឋប្បវេណីពុំបានចែងច្បាស់លាស់អំពីបញ្ហានេះ គេសង្កេតឃើញថាប្រសិនបើច្បាប់អនុញ្ញាតឲ្យមានការទទួលខុសត្រូវរួមគ្នារបស់សហព័ទ្ធចំពោះបំណុលដោយឡែក នោះវានឹងបង្កឲ្យមានភាពអយុត្តិធម៌ចំពោះសហព័ទ្ធម្ខាងទៀត ជាពិសេសបាត់បង់នូវផលប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គលនោះ ទោះបីជាកំពុងស្ថិតនៅក្នុងអំឡុងពេលដែលអាពាហ៍ពិពាហ៍មានអត្ថិភាព ឬពេលលែងលះក៏ដោយ។

តាមរយៈនេះ ការទទួលខុសត្រូវចំពោះបំណុលដោយឡែក ត្រូវតែជាកាតព្វកិច្ចរបស់សហព័ទ្ធណាម្ខាងដែលបានបង្កើតចំណងគតិយុត្តជាមួយតតិយជនដែលជាម្ចាស់បំណុល ក្នុងនាមខ្លួនជាកូនបំណុល។ ការកំណត់បែបនេះ បានសបញ្ជាក់ឲ្យឃើញថាការទទួលខុសត្រូវក្នុងស្ថានភាពបែបនេះ នឹងនាំមកនូវសមភាព និងភាពត្រឹមត្រូវ ដោយហេតុថាសហព័ទ្ធដែលបានបង្កើតចំណងគតិយុត្តជាមួយម្ចាស់បំណុល ជាអ្នកទទួលបានសិទ្ធិ ឬផលប្រយោជន៍ណាមួយ ហើយត្រូវតែទទួលបន្ទុកអនុវត្តកាតព្វកិច្ចនោះដោយខ្លួនឯង ដោយគ្មានការពាក់ព័ន្ធជាមួយនឹងទ្រព្យរបស់សហព័ទ្ធម្ខាងទៀត ឬទ្រព្យរួមដែលកើតមានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ឡើយ។

**កថាខណ្ឌទី២៖ បំណុលរួម**

បំណុលរួម ឬទ្រព្យអកម្មរួម គឺជាបំណុល ឬកាតព្វកិច្ចដែល៖

- កើតមានឡើងក្នុងអំឡុងពេលមានអត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍
- សោហ៊ុយសម្រាប់រៀបចំអាពាហ៍ពិពាហ៍
- សោហ៊ុយចំណាយសម្រាប់ជីវភាពគ្រួសារ
- សោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន
- សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម
- កាតព្វកិច្ច ឬករណីយកិច្ចផ្សេងទៀត ដែលសហព័ទ្ធទាំងសងខាងបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

- កាតព្វកិច្ច ឬករណីយកិច្ចផ្សេងទៀត ដែលសហព័ទ្ធណាម្ខាងជាអ្នកទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតលាយលក្ខណ៍អក្សរ ពីសហព័ទ្ធម្ខាងទៀត ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍
- កាតព្វកិច្ច ឬករណីយកិច្ចទាំងឡាយ ដែលសហព័ទ្ធទាំងសងខាងមានឆន្ទៈពិតប្រាកដនៅក្នុងការបង្កើតឡើង។[31]

## ផ្នែកទី២៖ ការទទួលខុសត្រូវចំពោះបំណុលរួមក្នុងស្ថានភាពនៃការលែងលះ

### កថាខណ្ឌទី១៖ ការទទួលខុសត្រូវដោយសាមគ្គីភាព

ជាគោលការណ៍ ប្តីប្រពន្ធ ត្រូវទទួលខុសត្រូវរួមគ្នា ចំពោះបំណុលទាំងឡាយដែលបានកើតឡើងក្នុងអំឡុងពេលដែលចំណងអាពាហ៍ពិពាហ៍មានអត្ថិភាព។ គ្មានសហព័ទ្ធម្ខាងណា អាចរួចផុតពីការទទួលខុសត្រូវឡើយ ដោយសហព័ទ្ធទាំងសងខាង ត្រូវទទួលបន្ទុកអនុវត្តកាតព្វកិច្ចទៅតាមភាគរៀងៗខ្លួន ប្រកបដោយភាពស្មោះត្រង់ និងសុចរិតក្នុងនាមខ្លួនជាកូនបំណុល។ ការកំណត់បែបនេះ មានគោលដៅដើម្បីរក្សាឲ្យបាននូវផលប្រយោជន៍របស់ម្ចាស់បំណុល ជាពិសេសបញ្ចៀសនូវការដាក់បន្ទុកធ្ងន់ធ្ងរទៅលើសហព័ទ្ធតែម្ខាង។[32]

ជាងនេះទៅទៀត ម្ចាស់បំណុល អាចទាមទារឲ្យសងបំណុលរបស់ខ្លួន ពីសហព័ទ្ធទាំងសងដោយអនុវត្តបានតែទៅលើទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធដែលជាកូនបំណុលតែប៉ុណ្ណោះ ដោយហេតុថាទ្រព្យសម្បត្តិរួមជាទ្រព្យសម្បត្តិដែលកើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ការបែងចែករវាងការអនុវត្តសិទ្ធិចំពោះទ្រព្យ

សម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក បានបង្កប់នូវគោលគំនិតមួយចំនួនដូចជា៖ ការការពារសិទ្ធិ និងផលប្រយោជន៍របស់សហព័ទ្ធទាំងសងខាងដែលមានទ្រព្យសម្បត្តិដោយឡែក ដោយសារទ្រព្យនោះមានអត្ថិភាពមុនរៀបអាពាហ៍ពិពាហ៍ ទ្រព្យដែលសហព័ទ្ធទទួលបានតាមរយៈសន្តតិកម្ម ប្រទានកម្ម អច្ច័យទាន ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងទ្រព្យដែលជាតម្លៃតបនៃការចាត់ចែងទ្រព្យសម្បត្តិដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍ សន្តតិកម្ម អច្ច័យទាន ព្រមទាំងប្រទានកម្ម។ លើសពីនេះទៅទៀត ការកម្រិតបែបនេះ បានបញ្ជាក់ឲ្យឃើញថាជាការជួយរក្សាទ្រទ្រង់ជីវភាពរស់នៅ និងទ្រព្យសម្បត្តិដែលនៅសេសសល់ក្រោយពេលធ្វើការលែងលះរួចបានក្លាយជាស្ថាពរ។

ដោយអនុលោមទៅតាមមាត្រា៣៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ បានបញ្ញត្តិដូចខាងក្រោម៖

ត្រូវធ្លាក់ទៅលើបន្ទុកនៃទ្រព្យសម្បត្តិរួម៖

- ការផ្គត់ផ្គង់គ្រួសារ និងចំណាយដើម្បីអប់រំ និងបណ្តុះបណ្តាលកូន។

---

[31] មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧។

[32] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥ គន្ថី៧ មាត្រា៩៧៥, ក្រសួងយុត្តិធម៌, ២០១០។

- បំណុល និងកាតព្វកិច្ចទាំងឡាយ ដែលសហព័ទ្ធទាំងពីរបានព្រមព្រៀងគ្នា នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬដែលសហព័ទ្ធណាម្នាក់បានសម្រេច ក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ដោយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត។
- ការថែទាំ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។

យើងខ្ញុំសូមធ្វើការបង្ហាញករណីអង្គហេតុជាក់ស្តែងមួយដែលមាន “ ក” ជាប្តី និង “ ខ” ជាប្រពន្ធ បានខ្ចីលុយធនាគារចំនួន ៥០.០០០ ដុល្លាអាមេរិក ហើយបានខ្ចីលុយពី “ ឃ” ដែលជាបងស្រីរបស់ “ ខ” ចំនួន ២០.០០០ ដុល្លាអាមេរិក ដើម្បីទិញដីមួយកន្លែងហៅថាដី L ដោយបច្ចុប្បន្នដីនេះមានតម្លៃ ១០០.០០០ ដុល្លាអាមេរិក តាមច្បាប់បំណុលនេះជាបំណុលដែកប្តីប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នា។ ដោយសារទំនាក់ទំនងក្នុងគ្រួសារមិនល្អឈានដល់ការបែកបាក់មិនអាចរួមរស់នឹងគ្នាបាន “ ខ” បានដាក់ពាក្យបណ្តឹងលែងលះដោយមានទ្រព្យសម្បត្តិរួម និងបំណុលរួមដូចតទៅ៖

ទ្រព្យសម្បត្តិរួមមាន៖

- A ដី L មានតម្លៃ ១០០.០០០ ដុល្លាអាមេរិក
- B រថយន្តតម្លៃ ១០.០០០ ដុល្លាអាមេរិក
- C ដី M មានតម្លៃ ៤០.០០០ ដុល្លាអាមេរិក

ហើយមានបំណុលដែលជំពាក់ធនាគារចំនួន ៥០.០០០ ដុល្លាអាមេរិក និងបំណុលជំពាក់ “ ឃ” ចំនួន ២០.០០០ ដុល្លាអាមេរិក។

“ ក” និង “ ខ” បានព្រមព្រៀងបែងចែកទ្រព្យរួមដូចតទៅ៖

- ដី L ជាកម្មសិទ្ធិរបស់ “ ខ” ដោយ “ ខ” ត្រូវបង់ប្រាក់ ៥០.០០០ ដុល្លាអាមេរិកដែលជំពាក់ធនាគារហើយ “ ខ” ត្រូវទទួលខុសត្រូវចំពោះបំណុលចំនួន ២០.០០០ ដុល្លាអាមេរិកដែលជំពាក់ “ ឃ” ។

ប្រសិនបើ ភាគីប្តីប្រពន្ធអនុវត្តតាមកិច្ចព្រមព្រៀងនោះ ប្រហែលជាពុំមានបញ្ហាកើតឡើងទេ ផ្ទុយទៅវិញ ប្រសិនបើភាគីណាមួយមិនអនុវត្ត តើអាចយកកិច្ចព្រមព្រៀង ឬសេចក្តីសម្រេចរបស់តុលាការមកចងបានដែរឬទេ? ផ្អែកតាមអង្គហេតុខាងលើ ប្រសិនបើ “ ខ” អនុវត្តតាមខ្លឹមសារនៃការព្រមព្រៀងដោយបានសងប្រាក់ ២០.០០០ ដុល្លាអាមេរិកទៅម្ចាស់បំណុល “ ឃ” ប៉ុន្តែ “ ក” មិនបានសងប្រាក់ ៥០.០០០ ដុល្លាអាមេរិកទៅធនាគារឡើយ តើធនាគារអាចទាមទារពី “ ខ” បានឬទេ? ក្នុងករណីនេះ ធនាគារនៅតែមានសិទ្ធិទាមទារប្រាក់ ៥០.០០០ ដុល្លាអាមេរិកពីប្តីប្រពន្ធ ឬពីប្តី ឬពីប្រពន្ធ ដោយលើកហេតុផលថា វាគឺជាបំណុលរួមដែលប្តីប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នា ហើយវាគឺជាកិច្ចព្រមព្រៀងបែងចែកបំណុលពុំមានអានុភាព ឬសេចក្តីសម្រេចអំពីការបែង

ចែកបំណុលមានភាពផ្ទុយច្បាប់ ហេតុនេះ " ខ" មិនអាចយកកិច្ចព្រមព្រៀង ឬសេចក្តីសម្រេចរបស់តុលាការមកសំអាងដើម្បីឲ្យខ្លួនគេចផុតពីការទទួលខុសត្រូវចំពោះបំណុលធនាគារនោះទេ។

### កថាខណ្ឌទី២៖ ការទាមទារអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល

ប្តីប្រពន្ធ ត្រូវទទួលខុសត្រូវដោយរួមគ្នាចំពោះបំណុលរួមហៅថា កាតព្វកិច្ចដោយសាមគ្គី។ ការទទួលខុសត្រូវដោយរួមគ្នា ឬសាមគ្គីភាពនេះបានបង្កើតនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលឲ្យកូនបំណុលដែលជាសហព័ទ្ធក្នុងការអនុវត្តកាតព្វកិច្ចរបស់ពួកគេ។

ម្ចាស់បំណុល អាចទាមទារឲ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគ ដោយព្រមគ្នា ឬជាបន្តបន្ទាប់។[33] ក្នុងករណីនេះប្រសិនបើម្ចាស់បំណុល ជ្រើសរើសប្តឹងទាមទារបំណុលទាំងអស់ពីកូនបំណុលដែលជាប្តីតែម្នាក់ឯង ប្តីមិនអាចលើកឡើងឲ្យទៅទាមទារមួយភាគនៃបំណុលសរុបរួមនោះពីប្រពន្ធបានឡើយ ដោយហេតុថាប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយរួមគ្នា ហើយមិនអាចបែងចែកបន្ទុកនៃការទទួលខុសត្រូវឡើយ ដោយផ្អែកទៅលើអត្ថន័យនៃមាត្រា ៩២១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧។

**ឧទាហរណ៍៖**

ប្តីនិងប្រពន្ធ បានសម្រេចចិត្តខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារមួយ ចំនួន ២០០០០ ដុល្លារដើម្បីទិញដីសាងសង់ផ្ទះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍បាន ៥ខែ ដោយមានសំបុត្រអាពាហ៍ពិពាហ៍ និងចុះបញ្ជីបានត្រឹមត្រូវស្របតាមច្បាប់។ ក្រោយមកអ្នកទាំងពីរក៏បានលែងលះ ដោយរស់នៅមិនចុះសម្រុងនឹងគ្នាជាប្តីប្រពន្ធ បន្ទាប់ពីខ្ចីបានរយៈពេល១ឆ្នាំ។ ទោះបីជាយ៉ាងនេះក៏ដោយ កម្ចី ២០០០០ដុល្លារដែលបានមកពីធនាគារ ជាបំណុលរួមដោយផ្អែកតាមច្បាប់ នាំឲ្យប្តីប្រពន្ធ ត្រូវទទួលខុសត្រូវរួមគ្នាចំពោះបំណុលនេះដោយសាមគ្គីភាព។

ប្រសិនបើប្តីប្រពន្ធមិនបានអនុវត្តកាតព្វកិច្ច ដែលសំដៅដល់ការសងប្រាក់មកធនាគារនោះទេ នាំឲ្យធនាគារដែលជាភាគីម្ចាស់បំណុល អាចអនុវត្តសិទ្ធិទាមទារដោយ៖

- អាចទាមទារប្រាក់ ២០០០០ ដុល្លាពីប្តីតែម្ខាង ឬ
- អាចទាមទារប្រាក់ ២០០០០ ដុល្លាពីប្រពន្ធតែម្ខាង ឬ
- អាចទាមទារប្រាក់ ២០០០០ ដុល្លាពីប្តី និងប្រពន្ធ ឬ
- អាចទាមទារប្រាក់ ១០០០០ ដុល្លាពីប្រពន្ធ និង ១០០០០ ដុល្លារទៀតពីប្តី។

ម៉្យាងវិញទៀត ប្រសិនបើប្តី ឬប្រពន្ធតែម្ខាងបានសងប្រាក់គ្រប់ចំនួន ២០០០០ ដុល្លារ នោះទៅធនាគាររួចហើយ នាំឲ្យកាតព្វកិច្ចរបស់ភាគីម្ខាងទៀតត្រូវរលត់ផងដែរ។

---

[33] មាត្រា ៩២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧។

ដូចនេះ នៅក្នុងសំណុំរឿងលែងលះ នៅពេលតុលាការសម្រេចពីការលែងលះ ឬការរំលាយចំណងអាពាហ៍ពិពាហ៍ និងមុនពេលដែលតុលាការសម្រេចអំពីការបែងចែកទ្រព្យរួម តុលាការត្រូវពិចារណា និងពិនិត្យផងដែរទៅលើបំណុលដែលសហព័ទ្ធទាំងសងខាង ឬសហព័ទ្ធម្ខាងបានបង្កើតឡើងក្នុងពេលដែលចំណងអាពាហ៍ពិពាហ៍មានអត្ថិភាព ដើម្បីធ្វើការទូទាត់សងទៅម្ចាស់បំណុល ក៏ដូចជាការការពារនូវសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុលថែមទៀតផង។ ទោះបីជាតុលាការបានបែងចែករួចហើយក៏ដោយ ក្នុងស្ថានភាពដែលមានបំណុលរួមបានកើតឡើង ម្ចាស់បំណុលមានសិទ្ធិប្តឹងទាមទារឲ្យសហព័ទ្ធណាម្នាក់សងបំណុលរបស់ខ្លួន ហើយបន្ទាប់មកសហព័ទ្ធដែលយកទ្រព្យដែលខ្លួនទទួលបានដើម្បីសង មានសិទ្ធិប្តឹងទាមទារឲ្យសហព័ទ្ធម្នាក់ទៀតធ្វើការទូទាត់សងមកឲ្យខ្លួនវិញ។[34]

[34]ពុំ រិទ្ធី, នីតិបេតិកភណ្ឌ និងគ្រួសារ, បោះពុម្ពលើកទី១ (ភ្នំពេញ៖ រោងពុម្ពវណ្ណ សភា, ២០១៩), ៧០។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការស្រាវជ្រាវប្រធានបទខាងលើ យើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថា ការបែងចែកទ្រព្យសម្បត្តិ និងការទទួលខុសត្រូវចំពោះបំណុលរួមក្នុងសំណុំរឿងលែងលះ ពិតជាមានភាពចាំបាច់ណាស់ក្នុងការលើកយកមកសិក្សាបកស្រាយដើម្បីឲ្យប្រជាពលរដ្ឋទូទៅមានការយល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់ គោលបំណង និងផលប្រយោជន៍អំពីការបែងចែកទ្រព្យសម្បត្តិ និងការទទួលខុសត្រូវចំពោះបំណុលរួមក្នុងសំណុំរឿងលែងលះទាំងកិច្ចសន្យា និងទាំងច្បាប់កំណត់ ពីព្រោះវាគឺជាកិច្ចចម្បងមួយដែលពួកគេគប្បីដឹង និងយល់នៅពេលដែលពួកគេដើរដល់ដំណាក់កាលលែងលះ។ ក្នុងនោះផងដែរ សហព័ទ្ធមានសិទ្ធិសេរីភាពក្នុងការកំណត់យកនូវទ្រព្យសម្បត្តិរបស់ពួកគេ តាមការព្រមព្រៀងលើកិច្ចសន្យាទ្រព្យសម្បត្តិ ឬតាមការកំណត់របស់ច្បាប់។ ខុសប្លែកគ្នាត្រង់ថាបើពួកគេយល់ព្រម គោរពតាមកិច្ចសន្យាទ្រព្យសម្បត្តិ នោះពួកគេតម្រូវឲ្យមានការព្រមព្រៀងបង្កើតឡើងនូវកិច្ចសន្យានោះ និងចុះបញ្ជីយ៉ាង ត្រឹមត្រូវស្របតាមនីតិវិធីនៅក្រសួងយុត្តិធម៌ ប៉ុន្តែបើពួកគេយល់ថាមិនចាំបាច់បង្កើតនូវកិច្ចសន្យាទ្រព្យសម្បត្តិទេនោះ គេក៏ មិនចាំបាច់បង្កើតវាទេ ហើយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់នឹងចូលខ្លួនមកអនុវត្តដោយស្វ័យប្រវត្តិ។

សម្រាប់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា វាមានគោលបំណងក្នុងការកំណត់យកអំពីសេរីភាព និងឆន្ទៈ របស់បុគ្គលឯកជនក្នុងការបែងចែកទ្រព្យសម្បត្តិរបស់ពួកគេ នៅមុនពេលនិងកំឡុងពេលដែលពួកគេរស់នៅជាមួយគ្នាជា ប្តីប្រពន្ធ។ ជាមួយគ្នាផងដែរ កិច្ចសន្យាទ្រព្យសម្បត្តិនេះអាចធ្វើការកែប្រែ ផ្លាស់ប្តូរ និងលុបចោលបានទៅតាមការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរដោយអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីប្រកាសនៅក្រសួងយុត្តិធម៌។ ម៉្យាងវិញទៀត វាមានអត្ថប្រយោជន៍សម្រាប់សហព័ទ្ធទាំងសងខាង ដើម្បីធ្វើការអះអាងជាមួយតតិយជន អំពីកម្រិតនៃទំហំ ទ្រព្យសម្បត្តិដែលពួកគេមាន និងជាការសម្រួលដល់តតិយជនផ្សេងទៀតផងដែរ ក្នុងការដឹងអំពីទំហំទ្រព្យសម្បត្តិរបស់ សហព័ទ្ធទាំងសងម្ខាង ឬតែម្ខាង នៅមុនពេលដែលគេធ្វើជំនួញឬពាណិជ្ជកម្មជាមួយប្តី ឬប្រពន្ធនោះ។ មិនតែប៉ុណ្ណោះ វាពិតជាមានសារៈសំខាន់ផងដែរ នៅពេលដែលសហព័ទ្ធទាំងសងខាងឈានទៅរកការលែងលះ។ នៅពេលដែលប្តីប្រពន្ធ មួយគូរនេះសម្រេចប្រកាន់យកនូវប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ពួកគេបានព្រមព្រៀងគ្នាលើការបែងចែកទ្រព្យសម្បត្តិទាំងរួម និងសម្បត្តិដោយឡែក រួមទាំងបានឯកភាពគ្នាទៅលើកាតព្វកិច្ចណាមួយជាកាព្វកិច្ចរួម និងកាតព្វកិច្ចណាមួយជាកាតព្វកិច្ចដោយឡែក។ ក្នុងន័យនេះ វាក៏បានជួយសម្រួលដល់នីតិវិធីតុលាការ ក្នុងការសម្រេចលើរឿងក្តីលែងលះគ្នានេះ ផងដែរ ព្រោះថា តុលាការនឹងសម្រេចទៅតាមអ្វីដែលមានកំណត់នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិនោះ តែប៉ុណ្ណោះ ប៉ុន្តែតុលាការនឹងពិចារណា មើលតទៅទៀតថាតើទ្រព្យសម្បត្តិដែលមានកំណត់នៅក្នុងខ្លឹមសារកិច្ចសន្យាទាំងនោះ មានផ្ទុយទៅនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងដែរឬទេ។

សម្រាប់ការបែងចែកទ្រព្យសម្បត្តិ និងការទទួលខុសត្រូវចំពោះបំណុលរួមក្នុងសំណុំរឿងលែងលះ តាមច្បាប់កំណត់វិញ គឺច្បាប់មានគោលបំណងចង់រក្សានូវចំណងអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋឲ្យរឹតតែមានភាពរឹងមាំតាមរយៈការចេះ ជួយសង្គ្រោះគ្នា សហការគ្នាក្នុងការរស់នៅ និងមានភាពសាមគ្គីប្តីប្រពន្ធតាមច្បាប់កំណត់មានអត្ថប្រយោជន៍ នៅពេល ដែលប្តីប្រពន្ធណាម្ខាង មានការធ្វេសប្រហែសក្នុងការដើរតួរជាប្តី ឬប្រពន្ធ និងជាម្តាយ ឬឪពុកសម្រាប់កូន នោះច្បាប់តម្រូវឲ្យពួកគេ មានការជួយសហការគ្នាទៅវិញទៅមក ដែលមានកំណត់នៅក្នុងបញ្ញត្តិច្បាប់ជាសំអាង។ ដោយឡែកនៅពេលលែងលះ សម្រាប់ប្តីប្រពន្ធដែលកំណត់យកនូវការបែងចែក

ទ្រព្យសម្បត្តិ និងការទទួលខុសត្រូវចំពោះបំណុលរួមក្នុងសំណុំរឿងលែងលះ តុលាការនឹងសម្រេចសេចក្តីទៅតាមការព្រមព្រៀង របស់គូភាគីនិងភស្តុតាងនានា ដែលបញ្ជាក់នូវទ្រព្យសម្បត្តិរបស់ពួកគេ ដែលខុសពីសហព័ទ្ធដែលមានកិច្ចសន្យាទ្រព្យសម្បត្តិ តុលាការសម្រេចតែទៅតាមអ្វីដែលមាននៅក្នុងខ្លឹមសារកិច្ចសន្យានោះតែប៉ុណ្ណោះ។

សរុបមក ការបែងចែកទ្រព្យសម្បត្តិ និងការទទួលខុសត្រូវចំពោះបំណុលរួមក្នុងសំណុំរឿងលែងលះ ត្រូវបានយកមកចាត់ចែង ប្រើប្រាស់ និងគ្រប់គ្រងក្នុងកម្រិតនៃកាសាមគ្គី និងជួយសង្គ្រោះគ្នាទៅវិញទៅមក ហើយការបែងចែកទៅឲ្យសហព័ទ្ធទាំងសងខាងទៅតាមសមាមាត្រនៃចំណែករបស់ខ្លួនរៀងៗខ្លួន។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងលំអិតទៅលើប្រធានបទខាងលើរួចមក យើងសង្កេតឃើញថា ដើម្បីឲ្យការអនុវត្តការបែងចែកទ្រព្យសម្បត្តិ និងការទទួលខុសត្រូវចំពោះបំណុលរួមក្នុងសំណុំរឿងលែងលះមួយបានត្រឹមត្រូវ ចាំបាច់ណាស់ត្រូវតែអនុវត្តទៅតាមនីតិវិធីដែល បានកំណត់នៅក្នុងខ្លឹមសារច្បាប់។ នៅពេលដែលពេលដែលច្បាប់បានតាក់តែងនូវកម្រងបញ្ញត្តិ មានការគិតគូរច្បាស់លាស់អំពី សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ ដើម្បីបំពេញក្នុងនាមជាប្តី ឬប្រពន្ធ និងបង្ការនូវហានិភ័យដែលអាចកើតមានឡើងនៅពេលមានបញ្ហាណាមួយ។ ជាការពិតណាស់នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ប្រជាជនមួយភាគធំ បានធ្វេសប្រហែសក្នុងការពិនិត្យ និងសិក្សាលើច្បាប់ដែលពាក់ព័ន្ធ នៅពេលដែលគេរៀបអាពាហ៍ពិពាហ៍ ឧទាហរណ៍ ការមិនចេញ ថ្លៃសោហ៊ុយសម្រាប់អាពាហ៍ពិពាហ៍ ការមិនមើលថែក្រុមគ្រួសារដូចជាការផ្គត់ផ្គង់នូវសំភារៈ ក៏ដូចជាផ្តល់ការស្រលាញ់ដល់សហព័ទ្ធរបស់ខ្លួន និងមានបញ្ហាមួយចំនួនទៀត តួយ៉ាងដូចការបែងចែក មិនស្មើភាពគ្នា ឬមិនអាចពិភាក្សាគ្នាបានលើទ្រព្យសម្បត្តិរួមនៅពេលលែងលះ។ ហេតុដូចនេះ ហើយទើបច្បាប់ខិតខំតាក់តែងនូវចំណុចទាំងឡាយ ដើម្បីជៀសវាងនូវបញ្ហានានា ដែលបាន រៀបរាប់ខាងលើ ប៉ុន្តែក្នុងនោះដែរក៏មានចន្លោះខ្វះខាតពីអ្នកអនុវត្តច្បាប់ ក្នុងការផ្សព្វផ្សាយឲ្យមានភាពទូលំទូលាយជាងនេះ ដល់ប្រជាពលរដ្ឋដែលបានដឹងអំពីបញ្ញត្តិទាំងនេះ ក៏ដូចជាពុំមានលទ្ធភាពក្នុងការដឹងនូវច្បាប់ដែលពាក់ព័ន្ធទាំងនេះផងដែរ។ ដូច្នេះហើយយើងខ្ញុំសុំលើកយកនូវការ សំណូមពរដល់រាជរដ្ឋាភិបាលនូវចំណុចដូចខាងក្រោមនេះ៖

- ជម្រុញឲ្យមន្ត្រីអត្រានុកូលដ្ឋាន និងមន្ត្រីដែលពាក់ព័ន្ធ ព្យាយាមឲ្យយោគយល់ និងណែនាំអំពីច្បាប់ដល់សហព័ទ្ធដែលទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ពីព្រោះគាត់អាចនឹងមិនដឹង ឬកម្រិតនៃការយល់ដឹងនៅមានកំនត់ ដែលអាចបង្កឲ្យមានវិវាទនានានៅពេលក្រោយ។
- ពង្រឹងនិងផ្សព្វផ្សាយច្បាប់ទៅអោយពលរដ្ឋ លើកកម្ពស់ការអានសៀវភៅ និងការចូលរួមនៅក្នុងកិច្ចការងារសង្គម។
- បង្ការការផ្តល់ព័ត៌មានខុស ឬការឲ្យប្រឹក្សា ពិគ្រោះយោបល់ខុស ពីសំណាក់មន្ត្រីមានសមត្ថកិច្ចទៅកាន់ប្រជាពលរដ្ឋ គប្បីមានវិធានការនានាដើម្បីទប់ស្កាត់នូវបញ្ហានេះ ដែលអាចកើតមានឡើងដោយថាហេតុ។

ជាចុងក្រោយ យើងខ្ញុំជានិស្សិតផ្នែកច្បាប់ នឹងព្យាយាមចែករំលែកនូវចំណេះដឹងក៏ដូចជាអាចផ្តល់ការប្រឹក្សា ឬធ្វើការពិភាក្សាណាមួយ ដល់ប្រជាជនក្នុងការយល់ដឹងនូវបញ្ហាទាំងនេះដើម្បីឲ្យពួកគាត់មានលទ្ធភាពក្នុងការប្រើប្រាស់ និងដោះស្រាយជាមួយដៃគូសហព័ទ្ធរបស់ពួកគេដែលប្រកបទៅដោយភាពត្រឹមត្រូវតាមផ្លូវច្បាប់ក៏ដូចជាចូលរួមក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិអោយមានការរីកចម្រើន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ លេខ ០៤ក្រ, ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។
- ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ ន/សរកម/០៧១០/០១៣, ១០ កក្កដា ២០១០។
- ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ០៩ សីហា ២០១៣។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៥, គន្ថីទី៧, ក្រសួងយុត្តិធម៌, ភ្នំពេញ, ២០១០។

## សៀវភៅ និងឯកសារផ្សេងទៀត

- រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ, ឆ្នាំ ២០១៧។
- ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២( សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ) ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី១. ខែ វិច្ឆិកា ឆ្នាំ ២០១៦។
- ព្រុំ រិទ្ធី, នីតិបេតិកភណ្ឌ និងគ្រួសារ, បោះពុម្ពលើកទី១ ភ្នំពេញ៖ រោងពុម្ពវណ្ណ សភា, ២០១៩, ៧០។
- ឯកសាររបស់វិភាគទានច្បាប់។

## គេហទំព័រ

- http://ciclg.com/kh/article/215 ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ( ការទទួលខុសត្រូវចំពោះបំណុលរួមរបស់ប្តីប្រពន្ធ )
- https://youtu.be/yXQCYDjcZAE Cambo TV HD, ការលែងលះ និងបែងចែកទ្រព្យសម្បត្តិ/,( ចូលទស្សនាថ្ងៃទី១៦ មិថុនា ២០២១ )។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

១. **ឧបសម្ព័ន្ធលេខ០១៖**ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

២. **ឧបសម្ព័ន្ធលេខ០២៖**ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

៣. **ឧបសម្ព័ន្ធលេខ០៣៖**ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង

៣.**ឧបសម្ព័ន្ធលេខ០៤៖**កិច្ចព្រមព្រៀងលែងលះគ្នា

៤.**ឧបសម្ព័ន្ធលេខ០៥៖**ពាក្យបណ្តឹងលែងលះ

# ឧបសម្ព័ន្ធលេខ០១
# ច្បាប់ស្តីពីការអនុវត្ត
# ក្រមរដ្ឋប្បវេណី

**មាត្រា ២៥.- ការប្រគល់សិទ្ធិឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស**

ទម្រង់នៃពាក្យសុំ និង បញ្ហាផ្សេងទៀតដែលចាំបាច់សម្រាប់ការចុះបញ្ជីនីតិបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ចំនួនសោហ៊ុយត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**មាត្រា ២៦.- សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១-កិច្ចការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ច របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។ បញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌ ។

**មាត្រា ២៧.- បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៨.- ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១-ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើរួមគ្នា និងជាលាយល័ក្ខណ៍អក្សរដោយប្តីប្រពន្ធ ឬដោយបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ ។

២-ពាក្យសុំត្រូវសរសេរចូលនូវឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ កាលបរិច្ឆេទចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ខ្លឹមសារនៃកិច្ចសន្យានោះ និង ចំណុចផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

៣-ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលាយល័ក្ខណ៍អក្សរ និងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៩._ ការប្រតិបត្តិការចុះបញ្ជី**

មន្ត្រីដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ២៦ (សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ) នៃច្បាប់នេះ មិនអាចប្រតិបត្តិការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធបានទេ រហូតទាល់តែអាចបញ្ជាក់បានថា ពាក្យសុំនោះត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា ៣០._ ការចុះបញ្ជីចំពោះការផ្លាស់ប្ដូរ ជាអាទិ៍**

១-ប្រសិនបើមានការផ្លាស់ប្ដូរនូវចំណុចដែលបានចុះក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីចំពោះការផ្លាស់ប្ដូរនោះ ។

២-ប្រសិនបើប្ដីប្រពន្ធបានលែងលះអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍-ពិពាហ៍ជាមួយគ្នាបានលែងលះកំជាប់ពាក្យប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធជាមួយគ្នា ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ជនដែលបានកំណត់ខាងក្រោមនេះ អាចដាក់ពាក្យសុំលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធតែឯកឯងបាន ប្រសិនបើមានហេតុដូចតទៅនេះ :

ក-ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ គឺ សហព័ទ្ធដែលនៅរស់ ។

ខ-ប្រសិនបើមានសេចក្ដីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិ ក្នុងសាលក្រម ឬ សាលដីកាលែងលះអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ គឺ អតីតសហព័ទ្ធណាម្នាក់ ។

គ-ប្រសិនបើតុលាការបានសម្រេចសេចក្ដីអំពីការបែងចែកទ្រព្យសម្បត្តិ ដោយការលែងលះអាពាហ៍ពិពាហ៍ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ហើយសេចក្ដីសម្រេចនោះចូលជាស្ថាពរ គឺ អតីតសហព័ទ្ធណាម្នាក់ ។

ឃ-ប្រសិនបើហេតុការណ៍ដែលលែងលះកំជាប់ពាក្យ ត្រូវបានបញ្ជាក់ដោយជាក់លាក់ នៅក្នុងសាលក្រម ឬ សាលដីកាស្ថាពរ ដែលសម្រេចអំពីការទាមទារដោយផ្អែកលើហេតុការណ៍លែងលះកំ-ជាប់ពាក្យ គឺ ភាគីណាម្នាក់ ។

៤-ចំណុចដែលត្រូវសរសេរចូលក្នុងពាក្យសុំ និង ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំ សម្រាប់ការដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៣១.- ការបញ្ជាក់**

បុគ្គលណាក៏ដោយ ក៏អាចសុំឲ្យធ្វើការបញ្ជាក់ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបានដែរ ដោយត្រូវបង់សោហ៊ុយ ។

**មាត្រា ៣២.- ការប្រគល់សិទ្ធិឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស**

ទម្រង់នៃពាក្យសុំ ការបញ្ជាក់ និង បញ្ហាផ្សេងទៀតដែលចាំបាច់សម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិ ប្ដីប្រពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ចំនួនសោហ៊ុយត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៣.- ការអនុញ្ញាតឲ្យអនីតិជនប្រកបអាជីវកម្ម**

ការអនុញ្ញាតឲ្យអនីតិជនប្រកបអាជីវកម្ម ដោយអ្នកមានអំណាចមេបា ដែលបានធ្វើឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកជាការអនុញ្ញាតឲ្យប្រកបអាជីវកម្មដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្ម) នៃក្រមរដ្ឋប្បវេណី ។

**មាត្រា ៣៤.- ការចាត់ចែងអំពីសាជីវកម្ម ឬមូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត**

១-សាជីវកម្មដែលមានទ្រព្យសម្បត្តិឯកពជ្យមានតម្លៃមិនតិចជាង ២០.០០០.០០០(ម្ភៃលាន) រៀល ហើយដែលជាសាជីវកម្មមានគោលបំណងមិនទាញយកចំណេញ ឬ មូលនិធិដែលមានទ្រព្យសម្បត្តិឯកពជ្យមានតម្លៃ មិនតិចជាង ២០០.០០០.០០០ (ពីររយលាន) រៀល ហើយដែលជាមូលនិធិ

# ឧបសម្ព័ន្ធលេខ០២

# ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

# ច្បាប់

## ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ

## ជំពូកទី ១

## បទញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយផ្អែកលើមាត្រា ៧ និងមាត្រា ៨ នៃរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា មានគោលដៅដាក់បទបញ្ញា និង ការពារការរៀបអាពាហ៍ពិពាហ៍ និង គ្រួសារ ធានាសមភាពរវាងសហព័ទ្ធក្នុងអាពាហ៍ពិពាហ៍ និងក្នុងជីវភាពគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្តាយក្នុងការចិញ្ចឹមថែរក្សាកូន និង ជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំកូន ដើម្បីអោយទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រឡាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម ។

**មាត្រា ២.-**

ហាមឃាត់ដាច់ខាតនូវអាពាហ៍ពិពាហ៍ដែលគូស្រករនៅក្មេងពេក អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ អំពើដែលមានឧបសគ្គដល់សេរីភាពនៃអាពាហ៍ពិពាហ៍ ។

## ជំពូកទី ២

## អំពីអាពាហ៍ពិពាហ៍

## ផ្នែកទី ១

## អំពីលក្ខខណ្ឌដែលត្រូវមាន ដើម្បីរៀបអាពាហ៍ពិពាហ៍

**មាត្រា ៣.-**

អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែល មិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។

**មាត្រា ៤.-**

បុរស និងនារី ដែលមានអាយុពេញលក្ខណៈច្បាប់ មានសិទ្ធិពេញលេញក្នុងការសំរេចអាពាហ៍ពិពាហ៍ ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតឡើយ ។

គ្មាននរណាមួយអាចបង្ខំបុគ្គលម្នាក់ អោយរៀប ឬរាំងមិនអោយរៀបអាពាហ៍ពិពាហ៍បានឡើយ បើអាពាហ៍-ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៥.-**

អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ ២០ ឆ្នាំឡើង នារីចាប់ពីអាយុ ១៨ ឆ្នាំឡើង ។

ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ ឆ្នាំ និង នារីដែលមានអាយុមិនទាន់ដល់ ១៨ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ។

**មាត្រា ៦.-**

មិនអាចរៀបអាពាហ៍ពិពាហ៍បាន :

-បុគ្គលមានភេទដូចគ្នា

-បុគ្គលគ្មានពលានុភាពនៃលិង្គ

-បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលបានជាដាច់

-ជនវិកលចរិក ជនមិនដឹងខុសត្រូវ

-បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ។

**មាត្រា ៧.-**

អាពាហ៍ពិពាហ៍ត្រូវហាមឃាត់រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬសាច់ចិញ្ចឹមក្តី ។

**មាត្រា ៨.-**

អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងសាខាញាតិ ទោះសាខាញាតិនោះ មានខាន់ស្លាក្តី ឥតខាន់ស្លាក្តី សាច់ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី រួមឪពុកម្តាយក្តី ជាញាតិលោហិតក្តី ឬជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់ទី ៣ នេះផង ។

ក្នុងករណីពិសេស ប្រសិនបើសហព័ទ្ធណាមួយស្លាប់ សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាញាតិពន្ធ ថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ បាន ។

**មាត្រា ៩.-**

ក្រោយពីអាពាហ៍ពិពាហ៍រលាយដោយមូលហេតុប្តីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬលែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងវិធវភាព "ភាពមេម៉ាយ" ចំនួន ៣០០ ថ្ងៃ គិតពីថ្ងៃដែលប្តីស្លាប់ ឬពីថ្ងៃប្រកាសសាលក្រមដែលសំរេចពីមោឃភាពនៃអាពាហ៍ពិពាហ៍ ឬ ពីថ្ងៃប្រកាសសាលក្រមជាស្ថាពរនៃការលែងលះ ។ ក្នុងករណីដែលតុលាការប្រជាជនបានចេញដីកាសំរេចអោយប្តីប្រពន្ធនៅបែកគ្នា នោះសាលក្រមនៃការលែងលះត្រូវគិតវិធវភាពតាំងពីថ្ងៃដែលចេញដីកានេះ ។

ប៉ុន្តែ បើនារីរៀបអាពាហ៍ពិពាហ៍មុនផុតរយៈពេល ៣០០ ថ្ងៃ ប្តីដែលរៀបអាពាហ៍ពិពាហ៍ថ្មីនេះ ត្រូវចាត់ទុកជាឪពុករបស់កូនដែលកើតក្នុងអាពាហ៍ពិពាហ៍ថ្មីនេះ លើកលែងតែមានការជំទាស់ពីប្តីមុនដោយមានភស្តុតាងច្បាស់លាស់ ។

**មាត្រា ១០.-**

ក្នុងករណីដែលសហព័ទ្ធណាមួយបាត់ខ្លួនកន្លងហួសពីមួយឆ្នាំ គិតពីថ្ងៃដែលបាត់ខ្លួននោះមកដោយគ្មានដំណឹងអ្វីសោះ

ហើយក៏គ្មាននរណាដឹងថាជននោះស្លាប់ ឬរស់ សហព័ទ្ធម្នាក់ទៀតអាចនឹងរៀបអាពាហ៍ពិពាហ៍ទៀតបាន បើផុតរយៈ ១៥ ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថាជននោះបានបាត់ខ្លួនពិតមែន ។

ជនណាក៏ដោយ មិនអាចប្តឹងសុំបដិសេធអាពាហ៍ពិពាហ៍ថ្មីនេះបានឡើយ ទោះបីសហព័ទ្ធដែលបាត់ខ្លួននោះត្រឡប់មកវិញក៏ដោយ ។

**មាត្រា ១១.-**

មុនពេលរៀបអាពាហ៍ពិពាហ៍ អនាគតប្តី ប្រពន្ធ ត្រូវប្តឹងដល់គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ខាងលំនៅរបស់នារី ដោយមានឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលចូលរួមផងក៏បាន ។

**មាត្រា ១២.-**

ប្រធាន ឬសមាជិកនៃគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ ក្នុងឋានៈជាមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រកាសផ្សាយជាសាធារណៈនូវអាពាហ៍ពិពាហ៍នោះ ដោយបិទប័ណ្ណប្រកាសនៅលំនៅរបស់នារី និងនៅទីស្នាក់ការឃុំ ឬសង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសពីរទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទនៅលំនៅរបស់បុរស និងនៅទីស្នាក់ការឃុំ ឬសង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសត្រូវចុះ :

១-ត្រកូល ឈ្មោះ អាយុ មុខរបរ និងលំនៅនៃអនាគតប្តី និងប្រពន្ធ

២-ត្រកូល ឈ្មោះ អាយុ មុខរបរ និងលំនៅរបស់ឪពុកម្តាយនៃអនាគតប្តី ប្រពន្ធ "បើឪពុក ឬម្តាយស្លាប់ត្រូវដាក់ថាស្លាប់ផង" ។

៣-រយៈពេលប្តឹងជំទាស់

**មាត្រា ១៣.-**

ប័ណ្ណប្រកាសត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ ដើម្បីអោយជនដែលមានផលប្រយោជន៍ក្នុងរឿងនេះដឹងឮ ហើយអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈ-ពេល ១០ ថ្ងៃ នេះពិធីអាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់ ។

**មាត្រា ១៤.-**

អាពាហ៍ពិពាហ៍នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និង នារីដែលស្ម័គ្រចិត្តយកគ្នាជាប្តីប្រពន្ធចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅរបស់នារី ។ កិច្ចសន្យានេះត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្តី ប្រពន្ធ និង សាក្សីគ្រប់អាយុការពីរនាក់ ។

## ជំពូកទី ៣
## អំពីការលែងលះគ្នា
### ផ្នែកទី ១
### អំពីមូលហេតុនៃការលែងលះគ្នា

**មាត្រា ៣៨.-**

ការលែងលះគ្នា គឺការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តី ប្រពន្ធដែលបានរៀបការពេញច្បាប់ ក្នុងពេលរស់នៅទាំងពីរនាក់ ។

**មាត្រា ៣៩.-**

ប្តី ឬប្រពន្ធ អាចប្តឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។

មូលហេតុជាអាទិ៍ មាន ដូចខាងក្រោមនេះ :

១-ការចុះចោលលំនៅសង្វាសដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបំរុងកូនសោះ ។

២-វាយដំ ឃោរឃៅ ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬចំពោះបុព្វញាតិរបស់សហព័ទ្ធនេះ ។

៣-មានចរិយាផ្ទុយពីសីលធម៌ ឬប្រព្រឹត្តអនាចារ

៤-អពលានុភាពនៃលិង្គ

៥-បែកគ្នាអស់រយ:ជាង ១ ឆ្នាំ ។

**មាត្រា ៤០.-**

ប្តីប្រពន្ធអាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន ។

### ផ្នែកទី ២
### អំពីនីតិវិធីនៃការលែងលះគ្នា

**មាត្រា ៤១.-**

ការសំរេចអំពីការលែងលះគ្នា ជាសមត្ថកិច្ចរបស់តុលាការប្រជាជនខេត្ត-ក្រុង ខាងលំនៅរបស់ចុងចម្លើយ ។

**មាត្រា ៤២.-**

បណ្តឹងសុំលែងលះគ្នា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចុះមូលហេតុដែលនាំអោយលែងលះគ្នា ។

បណ្តឹងនោះត្រូវដើមចោទយកទៅជូនតុលាការប្រជាជនខេត្ត-ក្រុងផ្ទាល់ក៏បាន ឬជូនគណ:ប្រជាជនឃុំឬសង្កាត់ខាងលំនៅរបស់ចុងចម្លើយដោយខ្លួនឯងផ្ទាល់ក៏បាន ។

ក្នុងករណីខាងក្រោមនេះ គណ:កម្មាធិការប្រជាជនឃុំ ឬសង្កាត់ត្រូវធ្វើការផ្សះផ្សាក្នុងរយ: ១៥ ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹង ។ បើផ្សះផ្សាពុំបានសំរេច ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្ត-ក្រុង ។

## ផ្នែកទី ៣
## អំពីអានុភាពនៃការលែងលះគ្នា

**មាត្រា ៦៩.-**

ការលែងលះគ្នារំសាយអានុភាពអាពាហ៍ពិពាហ៍ ចាប់តាំងពីថ្ងៃដែលការលែងលះគ្នានោះទៅជាស្ថាពរ ។

**មាត្រា ៧០.-**

ក្នុងករណីនៃការលែងលះគ្នា ទ្រព្យសម្បត្តិត្រូវបែងចែកទៅតាមការព្រមព្រៀងនៃភាគីទាំងសងខាង ។ បើគ្មានការព្រមព្រៀង សហព័ទ្ធម្នាក់ៗត្រូវយកតែទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន ដែលមានមុនរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមរតិកក្តី ជាអំណោយក្តី ជាអច្ច័យទានក្តី ក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ ។

ក្រៅពីនេះ សហព័ទ្ធម្នាក់ៗ មានសិទ្ធិត្រូវបានទ្រព្យសម្បត្តិរួមពាក់កណ្តាលម្នាក់ ។

ប៉ុន្តែក្នុងករណីពិសេស និងតាមសំណើរបស់សហព័ទ្ធណាមួយ តុលាការប្រជាជនអាចសំរេចសេចក្តី ចែកទ្រព្យសម្បត្តិរួម ផ្សេងពីគោលការណ៍ខាងលើបាន ដោយគិតទៅដល់ផលប្រយោជន៍របស់កូន និងផលិតកម្ម ។

ការងារនៃគេហកិច្ច ត្រូវចាត់ទុកជាមានតំលៃស្មើ និងការងារផលិតកម្ម ។

**មាត្រា ៧១.-**

ប្រសិនបើទ្រព្យសម្បត្តិផ្ទាល់របស់សហព័ទ្ធម្នាក់ត្រូវ សហព័ទ្ធម្នាក់ទៀតបំផ្លាញ សហព័ទ្ធនេះត្រូវតែសងតំលៃទ្រព្យនោះវិញ ។

**មាត្រា ៧២.-**

សាលក្រមដែលកាត់ឱ្យប្តីប្រពន្ធលែងលះគ្នានោះត្រូវសំរេចអំពីអំនាចមេបា ដែលត្រូវប្រគល់ឱ្យទៅឪពុក ឬទៅម្តាយ ហើយនឹងត្រូវសំរេចអំពីការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយ និងកូននោះផង ។

**មាត្រា ៧៣.-**

ដើម្បីផលប្រយោជន៍របស់កូន ការឱ្យភាគីណាមួយរក្សាកូន ត្រូវសំរេចតាមការយល់ព្រមនៃប្តីប្រពន្ធដែលលែងគ្នានោះ ។ តាមគោលការណ៍កូនដែលនៅបៅដោះត្រូវឱ្យទៅម្តាយរក្សា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នាលើការរក្សាកូន តុលាការប្រជាជនត្រូវសំរេច ។

**មាត្រា ៧៤.-**

ឪពុក ឬម្តាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ជួយបីបាច់រក្សា ជួយផ្តល់សោហ៊ុយ អប់រំ និងរៀនសូត្រដល់កូនតាមលទ្ធភាពរបស់ខ្លួន ។

កំរិតអាហារកិច្ចដែលត្រូវឱ្យទៅកូន ត្រូវសំរេចតាមការព្រមព្រៀងនៃសហព័ទ្ធដែលលែងលះគ្នា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេច ដោយផ្អែកទៅតាមលទ្ធភាពរបស់សហព័ទ្ធម្នាក់ៗ ។

# ឧបសម្ព័ន្ធលេខ០៣

# ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីមិនមែន ជាបណ្តឹង

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្ដី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ២ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៣ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃមាត្រា១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី) | តុលាការដែលបានកំណត់នៅក្នុងមាត្រា ១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី) |
| ៣ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៤ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការអនុញ្ញាតឱ្យអនុវត្តសិទ្ធិឧបាទេសកម្ម ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤២៣ (ល័ក្ខខ័ណ្ឌដើម្បីអនុវត្តសិទ្ធិឧបាទេសកម្ម) | តុលាការនៃលំនៅឋានរបស់កូនបំណុល |
| | ២ ការអនុញ្ញាតឱ្យលក់ដេញថ្លៃនូវវត្ថុដែលជាកម្មវត្ថុនៃការសង ដោយយោងតាមបញ្ញត្តិនៃមាត្រា៤៥៨ (សិទ្ធិលក់ដោយខ្លួនឯង) | តុលាការនៃកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច |
| ៤ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៧ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការសម្រេចសេចក្ដីជំនួសការយល់ព្រមចំពោះអាពាហ៍ពិពាហ៍របស់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា៩៥៣ (ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជន |
| | ២ ការចាត់ចែងទាក់ទងនឹងចំណែកបន្ទុកនៃសោហ៊ុយដែលកើតឡើងពីអាពាហ៍ពិពាហ៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧១ (ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍) | តុលាការនៃលំនៅឋានរបស់ភាគីម្ខាងទៀត |
| | ៣ ការសម្រេចសេចក្ដីអំពីការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ មាត្រា ៩៧៤ (ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ |
| | ៤ ការអនុញ្ញាតឱ្យចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៩៧៦ (ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ) | តុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ |
| | ៥ ពាក្យសុំលែងលះដោយការព្រមព្រៀង ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧៨ (ការលែងលះដោយការព្រមព្រៀង) | តុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ |
| | ៦ ការបែងចែកទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ |
| | ៧ ពាក្យសុំឱ្យបង្កើតសុំកូនពេញលេញ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០០៧ (ទម្រង់នៃការបង្កើតសុំកូនពេញលេញ) | តុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹម |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ឧបសម្ព័ន្ធលេខ០៤
# កិច្ចព្រមព្រៀងលៃលកភ្លា

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងស្តីពីការលែងលះ និង ការបែងចែកទ្រព្យសម្បត្តិ

**-ប្តីឈ្មោះ:** ឈ្មោះ.................................... កើតឆ្នាំ................. ជនជាតិខ្មែរ សញ្ជាតិខ្មែរ
អាសយដ្ឋានបច្ចុប្បន្ន...................................................ហៅកាត់ថាភាគី "ក" ។

និង

**-ប្រពន្ធឈ្មោះ:** ឈ្មោះ................................ កើតឆ្នាំ.................... ជនជាតិខ្មែរ សញ្ជាតិខ្មែរ
អាសយដ្ឋានបច្ចុប្បន្ន................................................... ហៅកាត់ថាភាគី "ខ" ។

ដោយហេតុថា

- ភាគី "ក" និងភាគី "ខ" បានរៀបការជាមួយគ្នាតាំងពីថ្ងៃទី.......... ខែ........... ឆ្នាំ............... ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍។
- ភាគី "ក" និងភាគី "ខ" រស់នៅមិនចុះសម្រុងនិងគ្នា ទោះធ្វើការផ្សះផ្សាយ៉ាងណាក៏មិនអាចត្រូវគ្នាវិញបាន បណ្តាលឱ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធ។

គូភាគីបានព្រមព្រៀងលែងលះ និង សិទ្ធិគ្រប់គ្រងកូនទៅតាមលក្ខខណ្ឌដូចខាងក្រោមនេះ៖

**ប្រការ១: ការលែងលះ**

ភាគី "ក " និងភាគី "ខ " បានព្រមព្រៀងរស់នៅបំបែកនីតិសង្វាស់ជាមួយគ្នាដោយស្ម័គ្រចិត្តចាប់ពីថ្ងៃចុះកិច្ចព្រមព្រៀងនេះ។

**ប្រការ២: ការបែងចែកទ្រព្យសម្បត្តិរួម**

តាំងពីរៀបអាពាហ៍ពិពាហ៍មក ភាគី "ក" និងភាគី "ខ" មិនមានទ្រព្យសម្បត្តិរួមនោះទេ។

**ប្រការ៣: ការទទួលខុសត្រូវលើបំណុល**

តាំងពីរៀបអាពាហ៍ពិពាហ៍មក ភាគី "ក" និងភាគី "ខ" មិនមានជំពាក់បំណុលរួមនោះទេ។

**ប្រការ៤: សិទ្ធិគ្រប់គ្រងកូន**

៤.១ ភាគី "ក" ជាអ្នកមានសិទ្ធិគ្រប់គ្រងកូនចំនួន ០១នាក់៖

១ ឈ្មោះ ............................ ភេទប្រុស កើតថ្ងៃទី................. ខែ............. ឆ្នាំ...............

៤.២ ភាគី "ខ" មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគី "ក" ត្រូវសម្រួលដល់ការអនុវត្តសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនដល់ភាគី "ខ" ។

**ប្រការ៥ : ការអនុវត្តរបស់ភាគី**

កិច្ចព្រមព្រៀងនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃផ្តិតមេដៃលើកិច្ចព្រមព្រៀងនេះតទៅ ហើយភាគីទាំងអស់សន្យាថា នឹងអនុវត្តតាមគ្រប់ប្រការទាំងអស់អោយបានល្អ។

**ប្រការ៦: ប្រសិទ្ធភាព**

ភាគីទាំងពីរបានអាន និង យល់រាល់ខ្លឹមសារដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ហើយយល់ព្រមផ្តិតមេដៃដោយស្មគ្រ័ចិត្ត និង គ្មានការបង្ខិតបង្ខំ។ ប្រសិនបើភាគីណាមួយរំលោភ លើកិច្ចព្រមព្រៀងនេះភាគីនោះ នឹងទទួលខុសត្រូវទៅតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជា ចាប់តាំងពីថ្ងៃចុះហត្ថលេខា ឬ ផ្តិតមេដៃនេះតទៅ។

កិច្ចព្រមព្រៀងនេះធ្វើឡើងជា (០៣) ច្បាប់ ៖

- ០១ច្បាប់ សម្រាប់ភាគី "ក "
- ០១ច្បាប់ សម្រាប់ភាគី "ខ "

ថ្ងៃទី................ ខែ.................. ឆ្នាំ................

ស្នាមមេដៃភាគី"ក"　　　　　　　　　　ស្នាមមេដៃភាគី"ខ"

..............................　　　　　　　　　　.................................

# ឧបសម្ព័ន្ធលេខ០៥
# ពាក្យបណ្ដឹងលែងលះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

**សូមគោរពចូលមក : ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ចាម**

*សូមទានជ្រាប ។*

**- ដើមចោទ:** ឈ្មោះ ..................... ភេទ................ កើតឆ្នាំ............ ជនជាតិខ្មែរ សញ្ជាតិខ្មែរ
មានទីលំនៅ..............................................................................។
លេខទូរស័ព្ទ.........................

**- ចុងចម្លើយ:** ឈ្មោះ ...................... ភេទ................. កើតឆ្នាំ.......... ជនជាតិខ្មែរ សញ្ជាតិខ្មែរ
មានទីលំនៅ..................................................................................។
លេខទូរស័ព្ទ...........................

**សាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញមានខ្លឹមសារដូចខាងក្រោម** :

– សុំលែងលះពីប្តីឈ្មោះ.................................. ។

**អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ**:

ការទាមទាររបស់នាងខ្ញុំផ្អែកលើ:

– សំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី............ ខែ.......... ឆ្នាំ...................... ។

**អង្គហេតុដែលជាមូលហេតុនៃការទាមទារ** :

ថ្ងៃទី.............. ខែ........... ឆ្នាំ............ នាងខ្ញុំបានចុះសំបុត្ររៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ......................។ ប៉ុន្តែចាប់តាំងពីរួមរស់ជាមួយគ្នាមក ពួកយើងទាំងពីរនាក់មិនមានភាពចុះសម្រុងគ្នាក្នុងការរស់នៅ និងអស់មនោសញ្ចេតនាជាប្តីប្រពន្ធគ្នាសោះឡើយ។ ឈ្មោះ ................ មិនបានបំពេញកាតព្វកិច្ចជាប្តីនោះទេ គាត់មិនដែលផ្តល់សុភមង្គលក្នុងគ្រួសារ និងផ្តល់តម្លៃឱ្យនាងខ្ញុំជាប្រពន្ធឡើយ។ កន្លងមកនាងខ្ញុំព្យាយាមសម្របខ្លួនរស់នៅជាមួយឈ្មោះ .................... ប៉ុន្តែដោយមិនអាចទ្រាំនឹងទង្វើរបស់គាត់ នាងខ្ញុំក៏បានស្នើសុំគាត់ឱ្យធ្វើការលែងលះតាមការព្រមព្រៀងតែគាត់មិនព្រម។ ហេតុនេះហើយទើបនាងខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីធ្វើការលែងលះពីឈ្មោះ.....................។ ក្នុងចំណងអាពាហ៍ពិពាហ៍ពួកយើងមិនមានកូននៅក្នុងបន្ទុកនោះទេ ចំពោះទ្រព្យសម្បត្តិ និងបំណុលក៏មិនមានដែរ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលពាក្យបណ្តឹង និងសម្រេចតាមការស្នើសុំរបស់នាងខ្ញុំ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីនាងខ្ញុំ ។

ថ្ងៃ....................................ខែ................. ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅកំពង់ចាម ថ្ងៃទី............ ខែ................. ឆ្នាំ២០២១

**ស្នាមមេដៃស្តាំ**

សូមភ្ជាប់ជូនមកជាមួយ
-សំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី.......... ខែ............ ឆ្នាំ..........
ចំនួន ០១ច្បាប់ (ថតចម្លង)

.................................